# 22 ប្រេង ជំងឺ និងសិទ្ធិមនុស្ស

**នៅក្នុងជំពូកនេះ :** **ទំព័រ**


ប្រេង និងសុខភាពសហគមន៍ . . . . . . . . . . 500
សហគមន៍ដែលរងការប៉ះពាល់ពីប្រេង រៀបចំការសិក្សាផ្នែកសុខភាពមួយ . . . . . . . . . . 500
ប្រេងបង្កបញ្ហាសុខភាពធ្ងន់ធ្ងរ . . . . . . . . . . 506
គ្រប់ផ្នែកទាំងអស់នៃផលិតកម្មប្រេង សុទ្ធតែមានគ្រោះថ្នាក់ . . . . . . . . . . 508
អណ្តាតភ្លើងឧស្ម័ន . . . . . . . . . . 511
សាច់រឿង : យើងអាចបញ្ឈប់អណ្តាតភ្លើងឧស្ម័នបាន! . . . . . . . . . . 512
រោងចក្រស្លប្រេង . . . . . . . . . . 513
ការកំពប់ប្រេង . . . . . . . . . . 514
សកម្មភាព : តើប្រេងរលាយចូលទឹកឬទេ? . . . . . . . . . . 514
ការសម្អាតប្រេងដែលកំពប់ . . . . . . . . . . 516
សាច់រឿង : ការសម្អាតប្រេងកំពប់ ធ្វើឲ្យកម្មករឈឺ . . . . . . . . . . 516
បង្កើតផែនការសុវត្ថិភាពសម្រាប់គ្រាអាសន្ន . . . . . . . . . . 518
ការស្តារដីដែលបានបំផ្លាញដោយប្រេងឡើងវិញ . . . . . . . . . . 520
សាច់រឿង : វិធីសាស្ត្រថ្មីក្នុងការសម្អាតប្រេងកំពប់? . . . . . . . . . . 520
យុត្តិធម៌ផ្នែកបរិស្ថាន . . . . . . . . . . 521
សាច់រឿង : ស្ត្រីឥវ៉ាប្រឆាំងនឹងការរុករកប្រេង . . . . . . . . . . 521
ប្រេង និងច្បាប់ . . . . . . . . . . 522
សាច់រឿង : បណ្តឹងប្រឆាំងនឹងក្រុមហ៊ុនតិចសាកូ . . . . . . . . . . 522

# ប្រេង ជំងឺ និងសិទ្ធិមនុស្ស



ប្រេងឆៅឬប្រេង គឺជាផ្នែកមួយនៃផលិតផលជាច្រើនដែលត្រូវបានប្រើប្រាស់រាល់ថ្ងៃ ដូចជាប្រេងសាំង, ឧស្ម័នប្រ៉ូប៉ាន ប្រេងកាត ប្រេងកម្តៅ និងកៅស៊ូក្រាលថ្នល់, ក៏ដូចជាប្លាស្ទិក ថ្នាំលាប ថ្នាំសម្លាប់សត្វល្អិត ថ្នាំរំលាយ និងផលិតផលសម្អាងផងដែរ។ សូម្បីតែសម្លៀកបំពាក់និងថ្នាំពេទ្យខ្លះ ក៏ត្រូវបានផលិតចេញពីប្រេងដែរ។ ប៉ុន្តែប្រេងគឺជាសារធាតុពុល និងមានផលប៉ះពាល់ដ៏គ្រោះថ្នាក់មកលើសុខភាពយើងនិងបរិស្ថាន ដោយរាប់ចាប់ពីមធ្យោបាយរុករកវា ជីកជញ្ជូន ចម្រាញ់ ក៏ដូចជារបៀបប្រើប្រាស់វានៅពេលចម្រាញ់រួច។

ប្រជាជនដែលរស់នៅតំបន់សម្បូរប្រេង សង្ឃឹមថាប្រេងនឹងផ្តល់ទ្រព្យសម្បត្តិដល់ពួកគេ។ ប៉ុន្តែក្នុងករណីជាច្រើន ទ្រព្យសម្បត្តិបានធ្លាក់ទៅលើក្រុមហ៊ុនប្រេងទៅវិញទេ ថែមទាំងបន្សល់ឲ្យប្រជាជនក្នុងសហគមន៍នូវភាពក្រីក្រ ការបំពុល ជំងឺ និងអំពើហឹង្សា ដែលហាក់ដូចជាកើតមានជានិច្ចនៅទីណាដែលបានរកឃើញប្រេង។ ដោយសារសេដ្ឋកិច្ចពិភពលោក ពឹងផ្អែកលើប្រេង ដូច្នេះឧស្សាហកម្មប្រេងមានឥទ្ធិពលលើរដ្ឋាភិបាលនិងគោលការណ៍អន្តរជាតិនានា។ ជាញឹកញាប់វាធ្វើឲ្យប្រជាជនក្រីក្រនៅក្នុងសហគមន៍សម្បូរប្រេង តស៊ូការពារខ្លួននិងដីរបស់ខ្លួន, ហើយប្រជាជននៅក្នុងសហគមន៍អ្នកមានឬកំពុងអភិវឌ្ឍន៍ តស៊ូនឹងការបំពុលខ្យល់។

ប្រេង ធ្យូងថ្ម និងឧស្ម័នធម្មជាតិ គឺជា**ឥន្ធនៈហ្វូស៊ីល**។ វាត្រូវបានបង្កើតចេញពីសាកសពរុក្ខជាតិនិងសត្វនានាដែលបានស្លាប់រាប់លានឆ្នាំមកហើយ ហើយបរិមាណរបស់វាមានកំណត់។ កាលពី១០០ឆ្នាំមុន ប្រេងបានក្លាយទៅជាប្រភពថាមពលដ៏ចម្បងសម្រាប់ប្រទេសស្ទើរតែទាំងអស់។ បច្ចុប្បន្ន ធនធានប្រេងក្នុងពិភពលោកយ៉ាងច្រើនត្រូវបានប្រើប្រាស់អស់។ ការដុតប្រេងឬឥន្ធនៈហ្វូស៊ីលដទៃទៀតច្រើនពេក បានបណ្តាលឲ្យមានការឡើងកម្តៅផែនដី(មើលទំព័រ33) ជាបញ្ហាបរិស្ថានដ៏ធំបំផុតមួយដែលពិភពលោកកំពុងប្រឈមសព្វថ្ងៃ។ ពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជននៅទូទាំងពិភពលោកកំពុងក្រើនរំឭកឲ្យបញ្ឈប់សេដ្ឋកិច្ចប្រេង រួចចាប់ផ្តើមអភិវឌ្ឍន៍ថាមពលទម្រង់ផ្សេងៗទៀតដែលស្អាតនិងមានស្ថិរភាពប្រសើរជាងនេះ(មើលជំពូក23)។

# ប្រេង និងសុខភាពសហគមន៍

នៅទីកន្លែងដែលបានរកឃើញប្រេង សេដ្ឋកិច្ចអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស ប៉ុន្តែវាជាសេដ្ឋកិច្ចនៃភាពវេទនា។ ការសាងសង់ជំរុំបណ្តោះអាសន្នមិនបានល្អ បង្កឲ្យមានបញ្ហាសង្គមជាច្រើន ដូចជាការជម្លៀសដោយបង្ខំ ភាពញៀនស្រា ជំងឺកាមរោគ និងមេរោគអេដស៍/ជំងឺអេដស៍( មើលទំព័រ474 )។ ក្រុមហ៊ុនប្រេងនិងរដ្ឋាភិបាលតែងតែលាងដៃរបស់ខ្លួនចេញពីសហគមន៍ទាំងឡាយដែលរងការខូចខាតបំផុតដោយសារការអភិវឌ្ឍន៍ប្រេង។ ពួកគេច្រើនតែទុកឲ្យសហគមន៍ទាំងនេះស្វែងយល់ពីទំហំនិងប្រភេទនៃគ្រោះថ្នាក់នានាដែលចេញពីការអភិវឌ្ឍន៍ប្រេង និងស្វែងរកមធ្យោបាយកែប្រែសុខភាពសហគមន៍របស់ខ្លួនឡើងវិញដោយខ្លួនឯង។

### ឧស្ម័នធម្មជាតិក៏បង្កបញ្ហាសុខភាពដែរ

ការដុតឧស្ម័នធម្មជាតិ បញ្ចេញកាបូនឌីអុកស៊ីតតិច( ជាមូលហេតុមួយនៃការឡើងកម្តៅផែនដី ) និងសារធាតុពុលដទៃទៀតតិចជាងការដុតប្រេង។ ប៉ុន្តែការខួងយកឧស្ម័នធម្មជាតិ គឺស្រដៀងគ្នានឹងការខួងយកប្រេងដែរ ហើយវានាំឲ្យមានបញ្ហាសង្គមជាច្រើនដូចគ្នា។ អ្វីៗស្ទើរតែទាំងអស់ដែលជាការពិតទាក់ទងនឹងប្រេងនៅក្នុងជំពូកនេះ ក៏ជាការពិតដែលទាក់ទងនឹងឧស្ម័នធម្មជាតិដែរ។

## សហគមន៍ដែលរងការប៉ះពាល់ពីប្រេង រៀបចំការសិក្សាផ្នែកសុខភាពមួយ

នៅឆ្នាំ១៩៩២ អ្នកលើកកម្ពស់សុខភាពមួយក្រុមនៅក្នុងព្រៃអាម៉ាហ្សូនក្នុងប្រទេសអេក្វាឌ័រ បានធ្វើការសិក្សាអំពីរបៀបដែលការខួងយកប្រេង ប៉ះពាល់ដល់សហគមន៍នានាក្នុងតំបន់។ ពួកគេដឹងថាក្រុមហ៊ុនប្រេងកំពុងបំផ្លាញដីរបស់ខ្លួន ប៉ុន្តែពួកគេយល់ដឹងតិចតួចអំពីការប៉ះពាល់នៃប្រេងមកលើសុខភាពប្រជាជន។ ដូច្នេះ ពួកអ្នកលើកកម្ពស់សុខភាព បានចាប់ផ្តើមប្រមូលព័ត៌មាននៅក្នុងក្រុងនិងភូមិនានា។




ការសិក្សាផ្នែកសុខភាពមួយនេះ បានចំណាយពេលវេលានិងកម្លាំងយ៉ាងច្រើន។ នៅពេលចាប់ផ្តើម អ្នកលើកកម្ពស់សុខភាពមិនបានដឹងថាពួកគេនឹងដឹងពីអ្វីខ្លះទេ។ ពួកគេនិយាយប្រាប់រឿងរ៉ាវរបស់ខ្លួនទាំងឡាយដែលមានដាក់បញ្ចូលនៅក្នុងជំពូកនេះទាំងមូល។

រាប់ពាន់ឆ្នាំមកហើយ ភូមិភាគនេះគឺជាផ្ទះរបស់ពួកជនជាតិដើម។ នៅក្នុងព្រៃអាម៉ាហ្សូននេះ មានជនជាតិផ្សេងៗជាច្រើនដូចជា : Shuar-Achuar, Runa, Quichua, Huaorani, Siona-Secoya, និង Cofan។ វប្បធម៌នីមួយៗ មានភាសានិងសិល្បៈផ្ទាល់ខ្លួន និងចក្ខុវិស័យនៃសេចក្តីពិតរបស់ខ្លួន។ មុនសម័យទំនើប ពួកកុលសម្ព័ន្ធអស់ទាំងនេះរស់នៅដោយសុខដុមជាមួយនឹងធម្មជាតិ។ បន្ទាប់មកភាពសុខដុមនេះក៏បានបែកបាក់។ ប្រសិនបើយើងចង់ដឹងថាតើមានអ្វីកើតឡើងចំពោះយើង យើងត្រូវតែក្រឡេកទៅមើលប្រវត្តិសាស្ត្ររបស់យើង។



នោះគឺជាពេលដែលចាប់ផ្តើមបាត់បង់តុល្យភាពរវាងបុព្វបុរសរបស់យើង និងធម្មជាតិ។ ដំបូង ជនជាតិអេស្ប៉ាញបានរុករកមាសនិងប្រាក់នៅក្នុងដីរបស់យើង។ បុព្វបុរសរបស់យើងត្រូវបានបង្ខំឲ្យធ្វើជាទាសករ ដោយធ្វើការជីកមាសនិងប្រាក់ចេញពីដីរបស់យើង។ បន្ទាប់មកជនជាតិអង់គ្លេសក៏មកដល់។ ពួកគេមិនចង់បានមាសទេ ប៉ុន្តែចង់បានកៅស៊ូ។ ពួកគេបានយកពួកយើងធ្វើជាទាសករដើម្បីប្រមូលកៅស៊ូពីដីរបស់យើង។ បន្ទាប់ពីនេះ ក្រុមហ៊ុនប្រេងក៏មកដល់។ ពួកគេក៏ធ្វើដូចគ្នា។

យើងដឹងថាក្រុមហ៊ុនប្រេងកំពុងបំផ្លាញសុខភាពរបស់យើង។ ហេតុដូច្នេះហើយ ទើបអ្នកលើកកម្ពស់សុខភាពសម្រេចចិត្តធ្វើការសិក្សាលើការបំពុលនេះ និងអំពីរបៀបដែលវាប៉ះពាល់ដល់យើង។ យើងចង់ធ្វើការរួមគ្នាដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ច នយោបាយ និងវប្បធម៌។




អ្នកលើកកម្ពស់សុខភាពបានស្វែងយល់ថា ប្រជាជននៅក្នុងសហគមន៍ដែលបានបំពុលដោយប្រេង មានជំងឺច្រើនជាងប្រជាជននៅក្នុងសហគមន៍ដែលមិនបានបំពុល។ ស្ត្រីនៅក្នុងសហគមន៍ទាំងនោះមានការរលូតកូនជាច្រើនករណី។ កុមាររងគ្រោះដោយសារកង្វះអាហារូបត្ថម្ភ និងច្រើនតែស្លាប់នៅអាយុក្មេងៗ។ ប្រជាជនជាច្រើនមានជំងឺស្បែកដែលមិនព្រមជាសះស្បើយឡើយ។ (ដើម្បីរៀនបន្ថែមអំពីបញ្ហាសុខភាពបណ្តាលមកពីប្រេង សូមមើលទំព័រ506ទៅ507)។

នេះគ្រាន់តែជាបញ្ហាខ្លះៗដែលពួកគេបានស្វែងយល់ប៉ុណ្ណោះ។ បន្ទាប់ពីការសិក្សារបស់ខ្លួន ពួកគេបានបោះពុម្ពសៀវភៅដែលមានចំណងជើងថា "វប្បធម៌លិចលង់ក្នុងប្រេង"។




ក្រុមរបស់យើងមានគ្នា៦នាក់ : អ្នកលើកកម្ពស់សុខភាព៣នាក់(២នាក់ធ្វើការក្នុងសហគមន៍នានា, ម្នាក់ទៀតធ្វើការក្នុងមន្ទីរពិសោធន៍សុខភាព) និងអ្នកបច្ចេកទេសផ្នែកសុខភាព៣នាក់(វេជ្ជបណ្ឌិត, អ្នកជីវគីមី, និងអ្នកបច្ចេកទេសវេជ្ជសាស្ត្រ)។

**នេះគឺជាជំហាននានាដែលយើងបានធ្វើការសិក្សា ដូច្នេះអ្នកអាចធ្វើដូចគ្នានេះដែរ ៖**

**១. យើងប្រមូលព័ត៌មាន។**

យើងប្រមូលព័ត៌មានអំពីប្រភេទនៃការរុករកប្រេងក្នុងតំបន់របស់យើង, សារធាតុគីមីដែលបានប្រើប្រាស់, និងផលប៉ះពាល់សុខភាពពីសារធាតុគីមីទាំងនេះ។ យើងបានស្វែងយល់ថាសារធាតុគីមីទាំងនេះត្រូវគេដឹងថាបង្កឲ្យមានការរលូតកូន ពិការភាពពីកំណើត ជំងឺមហារីក និងជំងឺផ្សេងៗទៀត។ យើងក៏បានស្វែងយល់ទៀតថា ប្រជាជនមានជំងឺទាំងនេះដោយសារការផឹកទឹកដែលបានបំពុលដោយសារធាតុគីមីទាំងនេះ។



**២. យើងជ្រើសរើសសហគមន៍មួយចំនួនដែលគួរធ្វើការសិក្សា។**

យើងបានជ្រើសរើសសហគមន៍ចំនួន៧ ដែលមានការបំពុលទឹក ដោយសារការអភិវឌ្ឍន៍និងការចម្រាញ់ប្រេង។ ការជ្រើសរើសយកសហគមន៍ដែលមានការបំពុល គឺជាការងារងាយស្រួល ព្រោះសហគមន៍ស្ទើរតែទាំងអស់នៅក្នុងតំបន់របស់យើង សុទ្ធតែរងការបំពុលដោយអណ្តូងប្រេង ត្រពាំងកាកសំណល់ ឬស្ថានីយបូមទឹក។ យើងក៏បានជ្រើសរើសសហគមន៍៣ទៀតដែលគ្មានសកម្មភាពប្រេង ប៉ុន្តែមានលក្ខណៈស្រដៀងនឹងសហគមន៍ទាំង៧ខាងដើម។

**៣. យើងប្រមូលព័ត៌មានអំពីប្រវត្តិវេជ្ជសាស្ត្រនៃប្រជាជននៅក្នុងសហគមន៍ទាំងនេះ។**

យើងប្រមូលព័ត៌មានក្នុងរយៈពេល៤ឆ្នាំមុន ដើម្បីមើលថាតើក្នុងមួយឆ្នាំៗជំងឺណាខ្លះដែលកើតឡើងញឹកញាប់ជាងគេ។ យើងបានស្វែងយល់ថាប្រជាជនយ៉ាងច្រើនបានជួបឧប្បត្តិហេតុនានា និងជំងឺផ្សេងៗ។ រហូតដល់ពេលប្រមូលព័ត៌មានទាំងនេះ ទើបយើងបានដឹងថាពួកយើងជាច្រើននាក់សុទ្ធតែមានជំងឺ!



**៤. យើងបានទាក់ទងអ្នកវិទ្យាសាស្ត្រឲ្យជួយយើង... ប៉ុន្តែពួកគេមិនជួយឡើយ។**

យើងបានទៅទាក់ទងនៅមណ្ឌលសិក្សាផ្នែកសុខភាពក្នុងតំបន់ និងសុំពួកគេឲ្យជួយបង្រៀនអំពីមធ្យោបាយស្រាវជ្រាវដែលពេញនិយម។ ដំបូងពួកគេមានចំណាប់អារម្មណ៍ដែរ ប៉ុន្តែចុងក្រោយពួកគេមិនជួយយើង វិញ។ បន្ទាប់មកយើងបានសុំសាលាពេទ្យមួយនៅក្បែរៗនោះ ប៉ុន្តែពួកគេក៏មិនជួយយើងដែរ។ សិស្សនៅទីនោះបានផ្តល់យោបល់ឲ្យយើងសិក្សាលើសារធាតុគីមីនៅក្នុងទឹកផឹក។ ដោយសារវិធីសាស្ត្រនេះមានតម្លៃថ្លៃ ដូច្នេះពួកគេបានផ្តល់យោបល់ឲ្យយើងរៃអង្គាសប្រាក់ពីប្រទេសខាងក្រៅ។



**៥. យើងរៀបចំការជួបប្រជុំរវាងប្រជាជននៅក្នុងសហគមន៍ទាំងអស់ក្នុងតំបន់របស់យើង។**

យើងពន្យល់ពួកគេពីមូលហេតុដែលយើងចង់ធ្វើការសិក្សានេះ និងសួរពួកគេថាតើត្រៀមលក្ខណៈជួយយើងឬទេ។ នៅចង់បញ្ចប់នៃការប្រជុំ មនុស្សគ្រប់គ្នាបោះឆ្នោតគាំទ្រការសិក្សានេះ។ យើងបានរៀបចំគណៈកម្មាធិការមួយដែលរួមមានអ្នកលើកកម្ពស់សុខភាព, ប្រជាជនមកពីសហគមន៍ខុសៗគ្នា, និងប្រជាជនដែលមានចំណេះដឹងអំពីរបៀបដែលសារធាតុគីមីប៉ះពាល់ដល់ប្រជាជននិងបរិស្ថាន, ដើម្បីអនុវត្តការសិក្សានេះ និងវិភាគលើលទ្ធផលដែលប្រមូលបាន។




**៦. យើងបង្កើតផែនការការងារមួយ។**

យើងបានគ្រោងពេលវេលា៩ខែសម្រាប់ការសិក្សានេះ។ រៀងរាល់១៥ថ្ងៃម្តង យើងនឹងទៅធ្វើការក្នុងសហគមន៍ខុសៗគ្នា យើងសម្រាកនៅទីនោះរយៈពេល៣ឬ៤ថ្ងៃ។ យើងនឹងស្ទង់មតិប្រជាជនក្នុងសហគមន៍ និងប្រមូលគំរូឈាម ទឹកនោម និងលាមក ដើម្បីធ្វើតេស្ត៍។ នៅពេលយើងទទួលបានលទ្ធផលតេស្ត៍ពីមន្ទីរពិសោធន៍នៅក្នុងទីក្រុង យើងនឹងត្រឡប់ទៅសហគមន៍នោះវិញដើម្បីប្រាប់ពីលទ្ធផលនេះ។ នេះជាចំណុចសំខាន់ណាស់ព្រោះវាធ្វើឲ្យយើងសម្រេចចិត្តរួមគ្នា។ យើងក៏បានគ្រោងការប្រជុំរៀងរាល់២ខែម្តង ដែលពេលនោះគណៈកម្មាធិការសម្របសម្រួល និងអ្នកតំណាងសហគមន៍ អាចជជែកគ្នាអំពីដំណើរការនៃការសិក្សា។

**៧. យើងស្វែងរកមូលនិធិសម្រាប់ការងារយើង និងការចំណាយលើមន្ទីរពិសោធន៍។**

យើងបង្កើតគណៈកម្មការមួយដើម្បីស្វែងរកប្រាក់។ បន្ទាប់ពីការស្វែងរកជាច្រើនកន្លែង យើងបានទទួលប្រាក់សម្រាប់ការសិក្សា ពីវេជ្ជបណ្ឌិតមួយក្រុមនៅប្រទេសអេស្ប៉ាញ។

**៨. យើងបង្កើតផែនទីនៃសហគមន៍ទាំងឡាយ។**

ប្រជាជននៅក្នុងសហគមន៍នីមួយៗ បានបង្កើតផែនទីរៀងៗខ្លួនដែលបង្ហាញពីអណ្តូងប្រេង ទឹកដែលរងការបំពុល និងទីតាំងភូមិនិងកសិដ្ឋាន។ ក្នុងពេលជាមួយគ្នា យើងបានបង្កើតបញ្ជីមួយដែលកត់ត្រាព័ត៌មានប្រជាជនទាំងអស់នៅក្នុងសហគមន៍នីមួយៗ។ បញ្ជីនេះរួមមានឈ្មោះ អាយុ និងភេទ របស់ប្រជាជនម្នាក់ៗ។

**៩. យើងចាប់ផ្តើមចុះទស្សនកិច្ចនៅសហគមន៍ និងអនុវត្តការសិក្សា។**

ជំនួសឲ្យការបញ្ជូនគំរូទៅទីក្រុង យើងបានបង្កើតមន្ទីរពិសោធន៍នៅក្នុងសាលារៀនមួយក្នុងសហគមន៍ដែលនៅទីនេះយើងធ្វើតេស្តឈាម ទឹកនោម និងលាមក។ (អ្នកត្រូវការឧបករណ៍មន្ទីរពិសោធន៍ និងការបណ្តុះបណ្តាលមួយចំនួនដើម្បីធ្វើតេស្តនេះ ដូច្នេះយើងនឹងមិនពន្យល់អំពីវានៅទីនេះទេ)។ រៀងរាល់ព្រឹក យើងធ្វើដំណើរពីផ្ទះមួយទៅផ្ទះមួយដើម្បីប្រមូលគំរូ។ បន្ទាប់មក ក្រុមមួយទៀតធ្វើដំណើរទៅផ្ទះនីមួយៗដើម្បីប្រមូលព័ត៌មាន ហើយអ្នកលើកកម្ពស់សុខភាពបានពិនិត្យសុខភាពឲ្យមនុស្សម្នាក់ៗ។



**១០. នៅពេលយើងប្រមូលបានព័ត៌មានទាំងអស់ យើងតម្រៀបវាតាមលំដាប់។**

បន្ទាប់មកយើងប្រៀបធៀបព័ត៌មាននៃសហគមន៍ដែលរងការបំពុល ជាមួយសហគមន៍ដែលមិនរងការបំពុល។ យើងប្រៀបធៀបចំណុចជាច្រើន : ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពនយោបាយ វប្បធម៌ និងសំខាន់បំផុតគឺសុខភាពប្រជាជន។

**១១. ជំហានចុងក្រោយគឺយើងសរសេរវាទុក និងពិភាក្សាទាំងអស់គ្នា។**

បែបនេះជួយឲ្យសហគមន៍ទាំងអស់ដែលពាក់ព័ន្ធ សម្រេចចិត្តពីការចាត់វិធានការនានាដើម្បីកែលម្អសុខភាពរបស់យើង។



# ការសិក្សាផ្នែកសុខភាព នាំឲ្យមានសកម្មភាពសហគមន៍

ការងាររបស់អ្នកលើកកម្ពស់សុខភាព បានបង្ហាញប្រជាជនថា បញ្ហាសុខភាពជាច្រើនរបស់ពួកគេ គឺត្រូវបានបង្កឡើងដោយការបំពុលពីប្រេង។ សារធាតុគីមីបុលពីប្រេង ត្រូវបានរកឃើញនៅក្នុងទឹកនិងដី និងនៅក្នុងឈាម ទឹកនោម និងលាមកប្រជាជន។ ការដឹងពីចំណុចទាំងនេះ ជួយឲ្យពួកគេធ្វើការងារឆ្ពោះទៅរកដំណោះស្រាយមួយ។ ពួកគេបានស្វែងយល់ថា ដរាបណាការបំពុលនៅតែបន្តកើតមាន នោះពួកគេពិតជាពិបាកនឹងទទួលបានទឹកសុវត្ថិភាព អាហារសុខភាព ឬខ្យល់ស្អាត។

ក្រុមមួយដែលហៅខ្លួនឯងថា គណៈកម្មាធិការនៃប្រជាជនដែលរងការប៉ះពាល់ ត្រូវបានបង្កើតឡើងដើម្បីសរសេរលិខិតទៅរដ្ឋាភិបាល ស្នើសុំអន្តរាគមន៍។ ហើយការប្រមូលផ្តុំរបស់អ្នកលើកកម្ពស់សុខភាពនៅតែបន្តគាំទ្រសុខភាពប្រជាជន និងបង្ហាញពីរបៀបដែលបញ្ហាសុខភាពរបស់ពួកគេត្រូវបានបង្កឡើងដោយប្រេង។


**អ្នកលើកកម្ពស់សុខភាព និងប្រជាជនផ្សេងៗទៀតនៅក្នុងសហគមន៍ បានដឹងថាការសិក្សារបស់ខ្លួន គ្រាន់តែជាការចាប់ផ្តើមនៃការតស៊ូដើម្បីសុខភាពនិងយុត្តិធម៌ប៉ុណ្ណោះ។**

អង្គការមួយទៀតដែលមានឈ្មោះថា រណសិរ្សការពារព្រៃអាម៉ាហ្សូន បានចាប់ផ្តើមបណ្តឹងផ្លូវច្បាប់លើក្រុមហ៊ុនប្រេងចំពោះការបំផ្លាញដែលគេបានបង្កឡើង។ (ដើម្បីស្វែងយល់បន្ថែមអំពីបណ្តឹងផ្លូវច្បាប់ សូមមើលទំព័រ522)។ ផ្នែកដ៏ធំនៃព្រៃទឹកភ្លៀង ត្រូវបានបំផ្លាញ ហើយច្បាប់បរិស្ថានដែលតម្រូវឲ្យជួសជុលការខូចខាត ក៏ត្រូវបានព្រងើយកន្តើយ។ ក្រុមហ៊ុនប្រេងដែលគ្រប់គ្រងដោយបរទេស គ្រាន់តែយកផលប្រយោជន៍របស់ខ្លួនបាន រួចក៏ចាកចេញទៅ។

ការសិក្សានិងបណ្តឹងផ្លូវច្បាប់របស់សហគមន៍ បានលើកទឹកចិត្តអង្គការដទៃទៀតឲ្យចូលរួមក្នុងការតស៊ូដើម្បីជួយសង្គ្រោះព្រៃទឹកភ្លៀង និងប្រជាជននៅទីនោះ។ សកលវិទ្យាល័យនិងសាលាមួយចំនួនក្នុងប្រទេសអេក្វាឌ័រ អង់គ្លេស និងសហរដ្ឋអាមេរិក បានធ្វើការសិក្សាបន្ថែមទៀតដើម្បីគាំទ្រដល់បណ្តឹងផ្លូវច្បាប់ប្រឆាំងនឹងក្រុមហ៊ុនប្រេង និងដើម្បីបង្ហាញថាប្រេងបង្កបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ។ ការសិក្សាទាំងនេះក៏បានជួយអ្នកនិពន្ធសៀវភៅឲ្យស្វែងយល់អំពីផលប៉ះពាល់នៃប្រេងមកលើសុខភាពមនុស្ស។

ប៉ុន្តែការងារសំខាន់ៗត្រូវបានធ្វើដោយអ្នកលើកកម្ពស់សុខភាពរួចហើយ។ តាមរយៈការរៀនធ្វើការសិក្សាដោយខ្លួនឯងអំពីផលប៉ះពាល់នៃប្រេង ពួកគេបានធ្វើការលើបញ្ហាសកលដ៏សំខាន់មួយ។ តាមរយៈការបង្ហាញថាសុខភាពរបស់ប្រជាជនបានរងការប៉ះពាល់ពីការបំផ្លាញព្រៃទឹកភ្លៀងដោយសារសាជីវកម្មប្រេងពហុជាតិ ពួកគេបានផ្សព្វផ្សាយពីបញ្ហាក្នុងស្រុកទៅឲ្យអន្តរជាតិដឹងឮ។ ពួកគេបានផ្តល់កម្លាំងដល់យើងនៅពេលយើងសរសេរសៀវភៅនេះ។

# ប្រេងបង្កបញ្ហាសុខភាពធ្ងន់ធ្ងរ

ក៏ដូចជាសារធាតុគីមីពុលដទៃទៀតដែរ បញ្ហាសុខភាពពីប្រេង អាចពិបាកនឹងបញ្ជាក់ឲ្យច្បាស់ ព្រោះវាត្រូវការពេលវេលាយូរក្នុងការប៉ះពាល់ប្រជាជន។ ប៉ុន្តែប្រជាជនដែលរស់នៅនិងធ្វើការនៅក្បែរកន្លែងខួងយកប្រេង និងកន្លែងស្លប្រេង ធ្លាប់នឹងការបំពុលខ្យល់និងទឹកដោយសារប្រេង។ ការខួងយកប្រេង ការស្លប្រេង និងការដុតប្រេងធ្វើជាឥន្ធនៈ សុទ្ធតែបណ្តាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរដូចមានរាយក្នុងបញ្ជីខាងក្រោម និងដូចរៀបរាប់លម្អិតនៅទំព័របន្តបន្ទាប់ទៀត ៖

- **ស្រវាំងភ្នែក** និងបញ្ហាភ្នែកផ្សេងៗទៀត
- **ឈឺក្បាល** សប្បាយចិត្តភ្លាមៗ អស់កម្លាំង និយាយមិនច្បាស់ ខូចខួរក្បាល សន្លប់យូរ
- **ប្រកាច់** និងស្លាប់ខុសធម្មតា
- **ឈឺច្រមុះ** និងឈាមច្រមុះ
- **ការបង្ករោគក្នុងត្រចៀក**
- **ជំងឺហឺត រលាកទងសួត រលាកសួត** និងជំងឺផ្លូវដង្ហើមដទៃទៀត
- ការបង្ករោគនិងមហារីកនៅ**សួតនិងបំពង់ក**
- **មានការប្រឈមខ្ពស់នឹងជំងឺរបេង**
- **គាំងបេះដូង**
- **បញ្ហារំលាយអាហារ** ដូចជាក្អួត ដំបៅ និងមហារីកក្រពះ
- **ខូចថ្លើម** តម្រងនោម និងខួរឆ្អឹងខ្នង
- **បញ្ហារដូវ** រលូតកូន ទារកកើតស្លាប់ និងពិការភាពពីកំណើត
- កន្ទួល ផ្សិត និងមហារីកលើ**ស្បែក**



នៅកន្លែងខ្លះ មនុស្សមួយចំនួនហិតចំហាយសាំងដើម្បីទទួលបានឥទ្ធិពលដូចថ្នាំញៀន។
បែបនេះគ្រោះថ្នាក់ណាស់។ ចំពោះអ្នកខ្លះ ការហឺតសាំងចូលយ៉ាងវែង
សូម្បីតែមួយដង្ហើម ក៏អាចបណ្តាលឲ្យស្លាប់ភ្លាមៗដែរ។

# ផលប៉ះពាល់យូរអង្វែងលើសុខភាព

## ប្រេងបង្កបញ្ហាសុខភាពបន្តពូជ

ការស្រូបចំហាយ ឬការលេបអាហារឬវត្ថុរាវដែលប្រឡាក់ប្រេងនិងឧស្ម័ន បណ្តាលឲ្យមានបញ្ហាសុខភាពបន្តពូជ ដូចជាការមករដូវមិនទៀងទាត់ រលូតកូន ទារកកើតស្លាប់ និងពិការភាពពីកំណើត។ បញ្ហាទាំងនេះអាចមានរោគសញ្ញាដំបូងៗ ដូចជាឈឺពោះ ឬរដូវមិនទៀង( មើលជំពូក16 សម្រាប់ព័ត៌មានបន្ថែម )។

## ប្រេងបង្កជំងឺមហារីក

ការប៉ះពាល់ជាមួយប្រេងនិងឧស្ម័នជាប្រចាំ បណ្តាលឲ្យកើតជំងឺមហារីក។ កុមារដែលរស់នៅក្បែរកន្លែងស្លប្រេង ងាយនឹងមានជំងឺមហារីកឈាម ជាងកុមារដែលរស់នៅឆ្ងាយ។ ប្រជាជនដែលរស់នៅក្នុងកន្លែងខួងប្រេង ងាយនឹងកើតជំងឺមហារីកក្រពះ ប្លោកនោម និងសួត ជាងប្រជាជនដែលរស់នៅកន្លែងដទៃ។ កម្មកររោងចក្រស្លប្រេង មានការប្រឈមខ្ពស់នឹងជំងឺមហារីកបបូរមាត់ ក្រពះ ថ្លើម លំពែង ជាលិកាតភ្ជាប់ ប្រូស្តាត ភ្នែក ខួរក្បាល និងឈាម។ ( សម្រាប់ព័ត៌មានបន្ថែមអំពីមហារីក សូមមើលជំពូក16 )។



**នៅតំបន់ខួងប្រេងក្នុងប្រទេសអេក្វាឌ័រ ប្រជាជនម្នាក់ក្នុងចំណោម៣នាក់ មានទម្រង់មួយចំនួននៃជំងឺមហារីក។**

នៅពេលក្រុមហ៊ុនតិចសាកូ ចាប់ផ្តើមខួងប្រេងក្នុងប្រទេសអេក្វាឌ័រ មិនទាន់ធ្លាប់ឮថាមានជំងឺមហារីកនៅក្នុងភូមិភាគនោះទេ។ ៤០ឆ្នាំក្រោយមក បុគ្គលិកសុខាភិបាលក្នុងសហគមន៍បានស្ទង់មតិលើសហគមន៍ចំនួន៨០ នៅក្នុងភូមិភាគចំនួន២នៃព្រៃអាម៉ាហ្សូនដែលត្រូវបានខួងយកប្រេងយ៉ាងច្រើនបំផុត។ ពួកគេរកឃើញថា ប្រជាជនម្នាក់ក្នុងចំណោម៣នាក់ មានទម្រង់មួយចំនួននៃជំងឺមហារីក។

# គ្រប់ផ្នែកទាំងអស់នៃផលិតកម្មប្រេង សុទ្ធតែមានគ្រោះថ្នាក់

ការយល់ដឹងអំពីផលប៉ះពាល់លើសុខភាពនិងបរិស្ថាន ក្នុងអំឡុងដំណាក់កាលនីមួយៗនៃផលិតកម្មប្រេង អាចជួយអ្នកក្នុងការឆ្លើយតបផ្សេងៗ។



## ការរុករកប្រេង

នៅពេលក្រុមហ៊ុនចាប់ផ្តើមស្វែងរកប្រេង ពួកគេកាប់រំលំដើមឈើ និងបំផ្លាញផ្ទះសម្បែងប្រជាជន។ ពួកគេសង់ផ្លូវ និងរាំងខ្ទប់ខ្សែទឹកនិងទន្លេ។ ការស្វែងរកប្រេងភាគច្រើនតម្រូវឲ្យធ្វើការបំផ្ទុះជាច្រើនលើកដើម្បីឲ្យដឹងថាមានអ្វីនៅក្នុងដី។ សកម្មភាពនេះហៅថា **ការធ្វើតេស្តដោយការរញ្ជួយ**។ ការធ្វើតេស្តដោយការរញ្ជួយ បំផ្លាញផ្ទះសម្បែង សត្វព្រៃ និងដី។

មុននឹងក្រុមហ៊ុនចាប់ផ្តើមស្វែងរកប្រេង ក្រុមនានាក្នុងសហគមន៍អាចទៅជួបមន្ត្រីរដ្ឋាភិបាលដើម្បីព្យាយាមបញ្ឈប់ការទន្ទ្រានដីធ្លីរបស់ខ្លួន, ទៅរៀនសូត្រពីអង្គការផ្សេងៗដែលមានបទពិសោធន៍ និងសហគមន៍ដែលរងការប៉ះពាល់ពីប្រេង, និងអប់រំមនុស្សគ្រប់គ្នាអំពីការគំរាមកំហែងចំពោះសុខភាពសហគមន៍។ ក្រុមហ៊ុនប្រេងត្រូវតែរៀបចំឯកសារនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន(EIA) (មើលសេចក្តីបន្ថែម ខ)។ ប្រសិនបើឯកសារEIA បង្ហាញថាគម្រោងនេះនឹងមានបំផ្លាញ សហគមន៍អាចទាមទារឲ្យក្រុមហ៊ុនបញ្ឈប់សកម្មភាព។ នៅក្នុងឯកសារEIA ក្រុមហ៊ុនប្រេងត្រូវតែដាក់បញ្ចូលនូវផែនការបោះចោលកាកសំណល់, ផែនការការពារទឹកក្នុងដីនិងលើដី, និងផែនការជូនដំណឹងនិងជម្លៀសប្រជាជនក្នុងសហគមន៍ជិតខាង ក្នុងករណីមានឧប្បត្តិហេតុអ្វីមួយ។

## ការខួងយកប្រេង



អណ្តូងប្រេងត្រូវបានខួង ដើម្បីទាញយកប្រេងចេញពីក្រោមដី។ ការខួងយកប្រេង អាចបណ្តាលឲ្យមានឆាបឆេះភ្លើង ការផ្ទុះ និងឧប្បត្តិហេតុផ្សេងៗទៀតដែលបង្កគ្រោះថ្នាក់ដល់កម្មករនិងសហគមន៍។ នៅពេលប្រេងកំពប់ វាបំពុលដល់ទឹកក្រោមដី និងផ្លូវទឹក, បង្កគ្រោះថ្នាក់ដល់រុក្ខជាតិនិងសត្វ, និងបំផ្លាញធនធាននានាសម្រាប់ការបរបាញ់ ការរកត្រី និងការធ្វើកសិកម្ម។

សហគមន៍អាចប្រើប្រាស់ម៉ាស៊ីនកាមេរ៉ា វីដេអូ ការផ្សាយតាមវិទ្យុ របាយការណ៍ជាអក្សរ និងសូម្បីតែរូបគំនូររបស់កុមារ ធ្វើជាឯកសារសម្រាប់បញ្ជាក់ពីគ្រោះថ្នាក់ពីការខួងយកប្រេង។ ឯកសារនេះអាចត្រូវបានប្រើប្រាស់ជាភស្តុតាង នៅពេលសហគមន៍ធ្វើការទាមទារឲ្យបញ្ឈប់ការខួងប្រេង និងការបំផ្លាញបរិស្ថាន, ឲ្យអនុវត្តនូវស្តង់ដារនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន, ឬឲ្យចាត់វិធានផ្លូវច្បាប់ចំពោះក្រុមហ៊ុនប្រេង។

# ការបំបែក

ប្រេងដែលខួងចេញពីដី មានលាយឡំជាមួយឧស្ម័ន លោហៈធ្ងន់ និងទឹកពុល។ គេត្រូវតែបំបែកប្រេងចេញពីសារធាតុទាំងនេះ។

ជាញឹកញាប់ ការចាក់ទឹកពុលចោល គឺជាមូលហេតុធំបំផុតនៃការបំពុល។ ច្បាប់ខួងប្រេងនៅក្នុងប្រទេសអ្នកមាន តម្រូវឲ្យចាក់ទឹកពុលនេះទៅក្រោមដីវិញ គឺមិនត្រូវចាក់ចោលលើដីទេ។ ការអនុវត្តបែបនេះគួរធ្វើឡើងនៅគ្រប់ប្រទេស។



កាកសំណល់ដទៃទៀតត្រូវបានបំបែកចេញពីប្រេង និងចាក់ទៅក្នុង**ត្រពាំងដែលមានការគ្រប់គ្រង។** ជាញឹកញាប់ក្រុមហ៊ុនប្រេងគ្មានធ្វើអ្វីក្រៅពីជីកត្រពាំងមួយ រួចចាក់ចូលនូវប្រេងឆៅ កាកសំណល់ពីការខួង ទឹកពុល និងកាកសំណល់ដទៃទៀតទេ។ ត្រពាំងទាំងនេះច្រើនតែជ្រាបទៅក្នុងដី ឬពេញហៀរ ធ្វើឲ្យកខ្វក់ដល់ទឹកក្រោមដី និងលើដី។

គួររៀបទ្រនាប់ស៊ីម៉ង់ត៍ក្នុងត្រពាំងទាំងនេះ។ មុននឹងដំណើរការប្រេងបញ្ចប់ ពួកគេត្រូវតែតាមដានត្រពាំងនេះមិនឲ្យជ្រាប កំពប់ និងត្រូវសម្អាតវាឲ្យរួចរាល់។

## អណ្តាតភ្លើងឧស្ម័ន

ឧស្ម័នដែលជាប់មកជាមួយប្រេង ត្រូវបានបំបែកចេញដោយការដុតវាចោល។ អណ្តាតភ្លើងឧស្ម័ន(មើលទំព័រ 511ទៅ512) ធ្វើឲ្យកម្មករ សហគមន៍ និងសត្វព្រៃ មានការប្រឈមនឹងការបំពុលដែលបណ្តាលឲ្យមានជំងឺមហារីក ជំងឺស្បែក ជំងឺហឺត រលាកទងសួត និងបញ្ហាសុខភាពផ្សេងទៀត។ អណ្តាតភ្លើងឧស្ម័នធ្វើឲ្យកខ្វក់ដល់ពពក, បណ្តាលឲ្យមាន "ភ្លៀងខ្មៅ" ដែលបំពុលដល់ប្រភពទឹក។

# ការដឹកជញ្ជូន និងការស្តុកទុក





ជាញឹកញាប់ ប្រេងបានកំពប់ក្នុងពេលដឹកជញ្ជូនតាមរយៈបំពង់បង្ហូរប្រេង រថយន្ត និងកប៉ាល់។ ប្រេងក៏អាចធ្លាយចេញពីអាងស្តុកផងដែរ។ ការកំពប់ប្រេងអាចបង្កការខូចខាតជាច្រើនឆ្នាំ ដល់ដីទឹកក្រោមដី សត្វ និងមនុស្ស។ ក្រុមហ៊ុនប្រេងគួរជូនដំណឹងដល់សហគមន៍នានានៅពេលកំពប់ប្រេង, គ្រប់គ្រងការកំពប់, និងសម្អាតវាភ្លាមៗ។ (ដើម្បីកាត់បន្ថយគ្រោះថ្នាក់ពីការកំពប់ប្រេង និងដើម្បីស្វែងយល់បន្ថែមអំពីការសម្អាតប្រេងកំពប់ សូមមើលទំព័រ514ទៅ519)។

ការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន គួរដាក់បញ្ចូលនូវផែនការសម្រាប់ការសាងសង់និងប្រើប្រាស់បំពង់បង្ហូរប្រេង។ អ្នកអាចបង្កើនការគាំទ្រក្នុងតំបន់ តាមរយៈការរៀបចំសកម្មភាពក្នុងសហគមន៍ទាំងឡាយដែលស្ថិតនៅតាមបណ្តោយបំពង់បង្ហូរ ឲ្យប្រឆាំងនឹងការអនុវត្តគ្មានសុវត្ថិភាពរបស់ក្រុមហ៊ុនប្រេង។



# ការស្លប្រេង

រោងចក្រស្លប្រេងគឺជាកន្លែងដែលប្រេងត្រូវបានផលិតទៅជាផលិតផលផ្សេងៗដូចជា សាំង ម៉ាស៊ូតនិងឥន្ធនៈកម្តៅ កៅស៊ូក្រាលថ្នល់ ប្រេងរំអិល និងប្លាស្ទិក។ រោងចក្រស្លប្រេង បញ្ចេញកាកសំណល់ពុលទៅក្នុងទឹក ដី និងខ្យល់។ ការបំពុលពីរោងចក្រស្លប្រេង អាចបណ្តាលឲ្យកើតជំងឺហឺត រលាកទងសួត មហារីក បញ្ហាបន្តពូជ និងការលូតលាស់ខួរក្បាលនិងប្រព័ន្ធសរសៃប្រសាទមិនប្រក្រតីចំពោះកុមារ។ ការបំពុលនេះក៏រួមចំណែកក្នុងការឡើងកម្តៅផែនដីផងដែរ។ (សម្រាប់ព័ត៌មានបន្ថែមអំពីការបង្ការនិងកាត់បន្ថយគ្រោះថ្នាក់ពីរោងចក្រស្លប្រេង សូមមើលទំព័រ455ទៅ458 និងទំព័រ513)។

# ការដុតប្រេងធ្វើជាឥន្ធនៈ

ការដុតប្រេងនិងឧស្ម័ននៅក្នុងរោងចក្រនិងយានយន្ត បង្កើតជាការបំពុលខ្យល់ក្នុងទម្រង់ផ្សេងៗគ្នា។ ឧស្ម័នមួយដែលត្រូវបានបង្កើតឡើង គឺកាបូនឌីអុកស៊ីត ដែលចាប់ស្ទាក់កម្តៅឲ្យស្ថិតនៅក្នុងខ្យល់។ នេះគឺជាមូលហេតុចម្បងមួយនៃការឡើងកម្តៅផែនដីដែលបណ្តាលឲ្យមានមហន្តរាយនានាដូចជា ទឹកជំនន់ ព្យុះ ភាពរាំងស្ងួត និងការឡើងកម្ពស់ទឹកសមុទ្រ។ វាក៏ប៉ះពាល់ដល់ដំណាំ សត្វ និងសត្វល្អិតផងដែរ ដែលអនុញ្ញាតឲ្យជំងឺផ្សេងៗ ដូចជាគ្រុនចាញ់ឆ្លងរាលដាលទៅតំបន់ថ្មីៗ។ នៅស្ថានីយសាំង និងក្នុងទីក្រុងកុះករ ប្រជាជនមានការប្រឈមនឹងចំហាយពុលដែលអាចបណ្តាលឲ្យកើតជំងឺមហារីក និងជំងឺផ្សេងទៀតជាច្រើន។



# អណ្ដាតភ្លើងឧស្ម័ន

នៅពេលប្រេងត្រូវបានខួងមកជាមួយឧស្ម័នធម្មជាតិ ក្រុមហ៊ុនប្រេងអាចដុតឧស្ម័ននោះដើម្បីបំបែកវាចេញពីប្រេង។ ការដុតឧស្ម័នធ្វើឲ្យមានអណ្ដាតភ្លើងយក្ខឆេះភ្លឺពេញមេឃ និងបង្កើតសំឡេងលាន់យ៉ាងខ្លាំង។ អណ្ដាតភ្លើងឧស្ម័ន មានគ្រោះថ្នាក់ ខ្ជះខ្ជាយ និងពុលជាខ្លាំង។

ក្រុមហ៊ុនប្រេងអាចលក់ឧស្ម័ន ជាជាងការដុតវាចោល។ ប៉ុន្តែបែបនេះកាន់តែត្រូវចំណាយយ៉ាងច្រើន និងមានការពិបាកជាខ្លាំង ព្រោះឧស្ម័នត្រូវរក្សាទុកក្រោមសម្ពាធ ដែលបង្កើនការប្រឈមនឹងការឆាបឆេះ និងផ្ទុះ។ ដូច្នេះក្រុមហ៊ុនប្រេងគ្រាន់តែដុតឧស្ម័ន ជាការស្រេច ព្រោះមិនចាំបាច់ចំណាយច្រើន ទោះបីវាបង្កើនគ្រោះថ្នាក់ដល់ប្រជាជននិងបរិស្ថានក៏ដោយ។

## សុខភាពនិងសុវត្ថិភាពជុំវិញអណ្ដាតភ្លើងឧស្ម័ន

អណ្ដាតភ្លើងឧស្ម័នទាំងអស់សុទ្ធតែបំពុលខ្យល់ និងអាចបង្កបញ្ហាសុខភាពផ្សេងៗ។ ប៉ុន្តែ អណ្ដាតភ្លើងឧស្ម័នខ្លះ មានគ្រោះថ្នាក់ជាងអណ្ដាតភ្លើងឧស្ម័នខ្លះទៀត។




ឧស្ម័នអាចត្រូវបានដុតយូរៗម្ដង ដើម្បីជាវិធានការសុវត្ថិភាពក្នុងការបង្ការការផ្ទុះ(ហៅថា **អណ្ដាតភ្លើងឧស្ម័នសុវត្ថិភាព**), ឬត្រូវបានដុតរៀងរាល់ថ្ងៃ ដែលជាផ្នែកមួយនៃប្រតិបត្តិការប្រេង(ហៅថា **អណ្ដាតភ្លើងឧស្ម័នជាប្រចាំ**)។ ប្រភេទនៃអណ្ដាតភ្លើងឧស្ម័ននីមួយៗ ទាមទារការឆ្លើយតបខុសគ្នា។

### អណ្ដាតភ្លើងឧស្ម័នសុវត្ថិភាព

រោងចក្រស្លប្រេងដុតអណ្ដាតភ្លើងឧស្ម័នសុវត្ថិភាពដើម្បីបន្ថយសម្ពាធនៅពេលមានឧស្ម័នច្រើនពេកនៅក្នុងបំពង់បង្ហូរប្រេង។ ទោះបីវាមិនកើតឡើងរាល់ពេលក៏ដោយ ការដុតបែបនេះនៅតែមានគ្រោះថ្នាក់យ៉ាងខ្លាំង! **ប្រសិនបើមានការដុតអណ្ដាតភ្លើងឧស្ម័នសុវត្ថិភាពនៅក្នុងសហគមន៍របស់អ្នក** គួរទាមទារឲ្យក្រុមហ៊ុនបញ្ជាក់ឲ្យដឹងជាមុនថាអណ្ដាតភ្លើងឧស្ម័ននឹងកើតឡើងនៅពេលណា។ ក្រុមហ៊ុនគួរតែផ្ដល់សញ្ញាព្រមានជាមុនជានិច្ច ដល់សហគមន៍ជិតខាង រយៈពេល២៤ម៉ោងមុននឹងដុតឧស្ម័ន។

**នៅពេលមានអណ្ដាតភ្លើងឧស្ម័ន** មនុស្សគ្រប់គ្នាគួរស្ថិតនៅឲ្យឆ្ងាយពីទីនោះ។ ចូលក្នុងផ្ទះ រួចបិទទ្វារ និងបង្អួចឲ្យជិត។ (សម្រាប់ព័ត៌មានបន្ថែមអំពីអ្វីដែលត្រូវធ្វើក្នុងពេលមានអាសន្ន សូមមើលទំព័រ457)។

### អណ្ដាតភ្លើងឧស្ម័នជាប្រចាំ

នៅកន្លែងខ្លះ ឧស្ម័នត្រូវបានដុតជារៀងរាល់ថ្ងៃ ព្រោះធ្វើបែបនេះក្រុមហ៊ុននឹងមិនចំណាយប្រាក់ច្រើន។ វាពិតជាពិបាកណាស់ដែលតម្រូវឲ្យប្រជាជនរស់នៅក្បែរអណ្ដាតភ្លើងឧស្ម័នជាប្រចាំ អនុវត្តការប្រុងប្រយ័ត្នបានគ្រប់ពេលនោះ។ វិធីតែមួយគត់ដើម្បីទទួលបានសុវត្ថិភាពពីអណ្ដាតភ្លើងឧស្ម័នជាប្រចាំ គឺត្រូវបញ្ឈប់វា។

## យើងអាចបញ្ឈប់អណ្ដាតភ្លើងឧស្ម័នបាន!

អណ្ដាតភ្លើងឧស្ម័នដែលធ្ងន់ធ្ងរក្នុងពិភពលោក បានកើតឡើងជាច្រើនឆ្នាំនៅតំបន់ដីសណ្ដទន្លេនីហ្សេ ក្នុងប្រទេសនីហ្សេរីយ៉ា។ អណ្ដាតភ្លើងឧស្ម័នដែលដុតដោយក្រុមហ៊ុនប្រេងអន្តរជាតិនានាក្នុងប្រទេសនីហ្សេរីយ៉ា បានបំផ្លាញជីវិតមនុស្សជាច្រើន។ ហើយសារធាតុពុលដែលបានបញ្ចេញដោយអណ្ដាតភ្លើងឧស្ម័នក្នុងប្រទេសនីហ្សេរីយ៉ា បានរួមចំណែកយ៉ាងច្រើនក្នុងការប្រែប្រួលអាកាសធាតុ និងការឡើងកម្ដៅផែនដី ច្រើនជាងការរួមបញ្ចូលគ្នានៃប្រភពទាំងអស់ក្នុងភូមិភាគសាហារាទៅទៀត។

បុរសម្នាក់ឈ្មោះថា អ៊ីបេកវ៉ា មកពីរដ្ឋរីវើស្តេត នៃប្រទេសនីហ្សេរីយ៉ា បាននិយាយថា : "ជាច្រើនឆ្នាំមកហើយ យើងបានរស់នៅជាមួយអណ្ដាតភ្លើងឧស្ម័នដែលដុតជាបន្តបន្ទាប់ឥតដាច់។ ដីស្រែចម្ការរបស់យើងត្រូវបានបំពុល។ យើងប្រឹងប្រែងធ្វើស្រែចម្ការយ៉ាងខ្លាំង ប៉ុន្តែទទួលបានទិន្នផលទាប។ ដំបូលផ្ទះរបស់យើងសឹកជាបន្តបន្ទាប់។ ខ្យល់របស់យើងក៏ត្រូវបានបំពុល។ កូនៗរបស់យើងមានជំងឺ។ សូម្បីតែទឹកភ្លៀងដែលយើងផឹក ក៏ប្រឡាក់ជាមួយលម្អងផ្សែងខ្មៅៗនៃអណ្ដាតភ្លើងឧស្ម័នដែរ។ យើងមិនអាចបន្តរស់នៅយ៉ាងវេទនាបែបនេះទៀតទេ"។

បន្ទាប់ពីការតស៊ូនិងតវ៉ាប្រឆាំងជាច្រើនឆ្នាំមក នៅឆ្នាំ២០០៥ អណ្ដាតភ្លើងឧស្ម័នត្រូវបានចាត់ទុកថាខុសច្បាប់នៅក្នុងតំបន់ដីសណ្ដទន្លេនីហ្សេ។ ចៅក្រមម្នាក់ចេញបញ្ជាថា រាល់ក្រុមហ៊ុនប្រេងទាំងឡាយនៅក្នុងប្រទេសនីហ្សេរីយ៉ាត្រូវតែបញ្ឈប់ការដុតអណ្ដាតភ្លើងឧស្ម័នជាបន្ទាន់ ព្រោះវាបង្កបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ ហើយវារំលោភលើសិទ្ធិក្នុងការទទួលបានបរិស្ថានសុខភាព។

**ប្រសិនបើមានអណ្ដាតភ្លើងឧស្ម័ននៅក្បែរអ្នក :**




- ពិភាក្សាអំពីគ្រោះថ្នាក់នៃអណ្ដាតភ្លើងឧស្ម័ន និងបង្កើតគណៈកម្មាធិការមួយដើម្បីប្ដឹងតវ៉ាទៅក្រុមហ៊ុននិងមន្ត្រីរដ្ឋាភិបាល។ ម្យ៉ាងទៀត គួរជជែកជាមួយបុគ្គលិកសុខភាព អ្នកសារព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាលនានា។
- កត់ត្រាព័ត៌មានផ្សេងៗនៃយុទ្ធនាការរបស់អ្នក។ លើកទឹកចិត្តប្រជាជនឲ្យកត់ត្រាពីពេលវេលានៃអណ្ដាតភ្លើងឧស្ម័ន ព្រមទាំងបញ្ហាផ្សេងៗដែលវាបង្កឡើង។
- រៀបចំការប្រជុំដើម្បីចែករំលែកពីកំណត់ត្រាទាំងនេះជាមួយសហគមន៍ដទៃ អ្នកសារព័ត៌មាន និងមន្ត្រីរដ្ឋាភិបាល។ កត់ត្រាអំពីការពិភាក្សារបស់អ្នកជាមួយពួកគេ។ ការកត់ត្រាទុកឬថតវីដេអូនូវអ្វីដែលមន្ត្រីរដ្ឋាភិបាលបាននិយាយ នឹងបង្ហាញថាអ្នកពិតជាយកចិត្តទុកដាក់នឹងបញ្ហានេះខ្លាំងណាស់។ សំខាន់បំផុត គឺមិនត្រូវចុះចាញ់ឡើយ!

សកម្មភាពទាំងនេះប្រហែលមិនអាចបញ្ឈប់អណ្ដាតភ្លើងឧស្ម័នភ្លាមៗទេ។ ប៉ុន្តែគោលដៅរួមនៃការបញ្ឈប់អណ្ដាតភ្លើងឧស្ម័ន អាចបង្រួបបង្រួមសហគមន៍ និងបង្កើនភាពរឹងមាំ ដើម្បីការពារសុខភាពមនុស្សគ្រប់គ្នាក្នុងពេលយូរអង្វែង។

# រោងចក្រស្លប្រេង

រោងចក្រស្លប្រេង គឺជាកន្លែងដែលប្រេងត្រូវបានផលិតទៅជាសាំង និងឥន្ធនៈផ្សេងៗទៀត, និងទៅជាសម្ភារៈផ្សេងៗដូចជាកៅស៊ូក្រាលថ្នល់ និងប្លាស្ទិក។ រោងចក្រស្លប្រេងគឺជាមូលហេតុចម្បងនៃការបំពុលខ្យល់ ចំពោះប្រជាជនដែលរស់នៅក្បែរនោះ និងធ្វើការជាមួយពួកគេ។ សារធាតុគីមីនៅក្នុងនិងនៅជុំវិញរោងចក្រស្លប្រេងបង្កជំងឺមហារីក, បញ្ហាបន្តពូជ, បញ្ហាដង្ហើម ដូចជាជំងឺហឺត និងជំងឺអំហ្សីសែមសួត, និងពិការភាពពីកំណើត, ព្រមទាំងបញ្ហាផ្សេងៗទៀត ដូចជាឈឺក្បាល ចង្អោរ វិលមុខ និងថប់អារម្មណ៍។ រោងចក្រស្លប្រេងក៏ជាមូលហេតុចម្បងនៃប្រភពឧស្ម័នដែលបណ្តាលឲ្យមានការឡើងកម្តៅផែនដី។

## ការធ្វើឲ្យរោងចក្រស្លប្រេងមានសុវត្ថិភាព

រោងចក្រស្លប្រេងមិនចាំបាច់ត្រូវបង្កបញ្ហាយ៉ាងធ្ងន់ធ្ងរបែបនេះទេ។ ការបំពុលអាចត្រូវបានបង្ការ ប្រសិនបើក្រុមហ៊ុនប្រេងធ្វើអ្វីគ្រប់យ៉ាងដើម្បីបង្ការឧប្បត្តិហេតុនានា និងគ្រប់គ្រងឧស្ម័ននិងវត្ថុរាវពុលនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការស្លប្រេង។ ប្រសិនបើអ្នកនិងសហគមន៍របស់អ្នក កំពុងព្យាយាមធ្វើឲ្យរោងចក្រស្លប្រេងមានសុវត្ថិភាព យុទ្ធនាការរបស់អ្នកអាចផ្តោតទៅលើគំនិតទាំងនេះមួយចំនួន :

**ការតាមដានការបំពុលខ្យល់** អាចកំណត់អំពីបញ្ហានានា និងបញ្ឈប់ភាពអាសន្នមុននឹងវាកើតឡើង។ ក្រុមហ៊ុនទាំងឡាយគួរតាមដានខ្យល់ និងឆ្លើយតបចំពោះបញ្ហាយ៉ាងឆាប់រហ័ស។ ប្រសិនបើពួកគេមិនតាមដានការបំពុលទេ សហគមន៍នានាអាចតាមដាន(មើលទំព័រ455ទៅ457)។



អាចជំនួស**អណ្តាតភ្លើងឧស្ម័ន**ដោយមធ្យោបាយសុវត្ថិភាព ដូចជាការកែប្រែឧស្ម័នសម្រាប់ប្រើប្រាស់ឡើងវិញ(មើលទំព័រ511)។

**អាងស្តុក**ប្រេងឆៅ សាំង និងសារធាតុដទៃទៀត ជួនកាលបញ្ចេញចំហាយពុលក្នុងពេលដែលចាក់វាចូលក្នុងអាង, ចាក់ចេញ, ឬសម្អាត។ ពួកគេអាចគ្រប់គ្រងចំហាយទាំងនេះដោយប្រើប្រាស់ឧបករណ៍ និងទម្រង់ការល្អប្រសើរមួយចំនួន។ ត្រូវតែត្រួតពិនិត្យមើលនិងជួសជុលអាងស្តុកនិងសន្ទះបិទបើករបស់វាជាប្រចាំ ដើម្បីបង្ការការធ្លាយទៅក្នុងខ្យល់និងទឹកក្រោមដី។

**កប៉ាល់ដឹកប្រេងនិងសាំង** អាចបញ្ចេញចំហាយទៅក្នុងខ្យល់ និងធ្លាយវត្ថុរាវទៅក្នុងទឹក។ គួរប្រើប្រាស់ប្រព័ន្ធសុវត្ថិភាពនៅគ្រប់ពេលទាំងអស់ ដើម្បីបង្ការការកំពប់និងចំហាយពុល។ កប៉ាល់បែបនេះគួរមានសម្បកទ្រនាប់ពីរឬបីជាន់ដើម្បីបង្ការការកំពប់។

**ទឹកសំណល់**ដែលផ្ទុកសារធាតុគីមីពុលច្រើនតែកំពប់ឬជ្រាបទៅក្នុងទឹកក្រោមដី។ តាមរយៈការសាងសង់និងថែទាំប្រព័ន្ធទឹកសំណល់ យើងអាចចៀសវាងបញ្ហាទាំងនេះបាន។

**ប្រេងឆៅដែលកខ្វក់**បង្កើតកាកសំណល់កាន់តែច្រើន ហើយបំពុលខ្យល់និងទឹក ជាពិសេសបើរោងចក្រត្រូវផលិតប្រេងកាន់តែសុទ្ធនិងស្រាល។ ការស្លប្រេងដែលស្អាត ធ្វើឲ្យមានការបំពុលតិច។

# ការកំពប់ប្រេង

នៅទីណាដែលមានប្រេង ទីនោះនឹងមានការកំពប់។ កប៉ាល់និងរថយន្តដឹកប្រេង មានឧប្បត្តិហេតុ រីឯបំពង់បង្ហូរប្រេង ធ្លាយ។ ការបង្ការការកំពប់ និងការសម្អាតវាភ្លាមៗនៅពេលកំពប់ គឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនប្រេង។

មានសុភាសិតមួយពោលថា : "ប្រេងនិងទឹកមិនរលាយចូលគ្នាទេ"។ ប៉ុន្តែនៅពេលប្រេងកំពប់ចូលក្នុងទឹក សារធាតុគីមីពុលនៅក្នុងប្រេង ពិតជារលាយចូលក្នុងទឹក ហើយស្ថិតនៅក្នុងនោះយ៉ាងយូរអង្វែង។ ស្រទាប់ប្រេងក្រាស់ៗអណ្តែតពាសពេញផ្ទៃទឹក និងបង្ស៊ាំងមិនឲ្យខ្យល់ចូលទៅក្នុងទឹក។ ត្រី សត្វ និងរុក្ខជាតិដែលរស់នៅក្រោមទឹក មិនអាចដកដង្ហើមបាន។ នៅពេលប្រេងកំពប់ចូលក្នុងទឹក សារធាតុគីមីដែលបន្សល់នៅក្នុងទឹក ធ្វើឲ្យទឹកគ្មានសុវត្ថិភាពសម្រាប់ផឹក ទោះបីយើងមើលឃើញនឹងភ្នែកថាប្រេងត្រូវបានយកចេញពីផ្ទៃហើយក្តី។

នៅពេលប្រេងកំពប់លើដី វាបំផ្លាញស្រទាប់ដីដោយការបង្ស៊ាំងខ្យល់មិនឲ្យចូល និងសម្លាប់វត្ថុមានជីវិតទាំងអស់ដែលធ្វើឲ្យដីមានជីជាតិ។ វាមានលក្ខណៈស្រដៀងគ្នានេះដែរ នៅពេលប្រេងប៉ះស្បែកយើងឬស្បែកសត្វ។ ប្រេងគ្របដណ្តប់ស្បែក និងបង្ស៊ាំងមិនឲ្យខ្យល់ចូល។ សារធាតុពុលនៅក្នុងប្រេង ចូលទៅក្នុងរាងកាយតាមរយៈស្បែក រួចបណ្តាលឲ្យមានជំងឺ។

**តើប្រេងរលាយចូលទឹកឬទេ ?**

សកម្មភាពនេះជួយឲ្យប្រជាជនយល់អំពីផលប៉ះពាល់នៃការកំពប់ប្រេងចូលក្នុងទឹក។

**ពេលវេលា :** ១ម៉ោងកន្លះ

**សម្ភារៈ :** ក្រឡកញ្ចក់ថ្លា, ទឹក, ប្រេងបន្លែ

1. ចាក់ទឹកចូលក្នុងក្រឡ។ ចាក់ប្រេងបន្លែ២ស្លាបព្រាបាយចូល។ ក្រឡុកក្រឡដើម្បីឲ្យវារលាយចូលគ្នា។ ទុកក្រឡចោលប្រហែល១ម៉ោង។

2. ត្រឡប់មកមើលក្រឡវិញ។ អ្នកនឹងឃើញថាប្រេងភាគច្រើនរងនៅខាងលើ។ ប្រេងបន្លែគ្មានគ្រោះថ្នាក់ទេ ប៉ុន្តែចូរអ្នកស្រមៃថាវាជាទឹកទន្លេដែលកំពប់ប្រេងចូល។ ចាប់ផ្តើមការពិភាក្សាអំពីផលប៉ះពាល់នៃការកំពប់ប្រេងចូលទន្លេ។ ស្រមៃថាត្រីកំពុងព្យាយាមរស់នៅក្នុងទន្លេដែលមានស្រទាប់ប្រេងពីលើដែលបង្ស៊ាំងខ្យល់និងពន្លឺថ្ងៃ។ ស្រមៃថាតើមានអ្វីកើតឡើងចំពោះសត្វស្លាបដែលព្យាយាមចាប់ត្រីនៅក្នុងទន្លេ។

3. យកស្លាបព្រាដួសត្រងប្រេងចេញពីផ្ទៃទឹក។ បន្ទាប់ពីអ្នកបានដួសវាចេញអស់ មើលថាតើនៅមានពពុះប្រេងនៅក្នុងទឹកឬទេ។ ពពុះទាំងនេះគឺជាប្រេងដែលលិច(រលាយ)ក្នុងទឹក។ ពិចារណាលើសុភាសិត "ប្រេងនិងទឹកមិនរលាយចូលគ្នា" ឡើងវិញ។ ពិភាក្សាជាមួយក្រុម អំពីអ្វីដែលនឹងកើតឡើងនៅពេលប្រេងពិតជារលាយចូលទឹកមែន។



### ការបំពុលទឹកដោយសារប្រេង

ការផឹកទឹកដែលមានប្រេង មានគ្រោះថ្នាក់ខ្លាំងណាស់។ ទឹកដែលចេញពីក្រោមដីនៅពេលខួងប្រេង ក៏ពុលខ្លាំងដែរ។

ឧបករណ៍ចម្រោះដែលសម្អាតប្រេងនិងសារធាតុគីមីពុលចេញពីទឹក មានតម្លៃថ្លៃណាស់។ ការដាំទឹក ការរម្ងាប់មេរោគដោយប្រើកម្តៅថ្ងៃ និងការលាយក្លរីនចូលក្នុងទឹក (មើលទំព័រ92ទៅ99) អាចសម្លាប់មេរោគ ប៉ុន្តែ**មិនអាច**បំបាត់ការបំពុលឡើយ។

ការលាយក្លរីន គឺធ្វើឲ្យការបំពុលដោយប្រេង កាន់តែធ្ងន់ធ្ងរទៅវិញទេ ព្រោះក្លរីនវាចូលរួមជាមួយសារធាតុគីមីមួយចំនួនហៅថា "ហ្វេណុល" (phenols) ដើម្បីបង្កើតជាទម្រង់សារធាតុគីមីមួយទៀតដែលកាន់តែពុល ហៅថា "ក្លរូហ្វេណុល" (chlorophenol)។

**ប្រសិនបើបានសម្អាតប្រេងដែលកំពប់ហើយក្តី ទោះបីអ្នកមើលមិនឃើញប្រេងនៅក្នុងទឹកក៏ដោយ វាក៏ប្រហែលនៅមិនទាន់មានសុវត្ថិភាពដែរ។** សារធាតុពុលជាច្រើននៅក្នុងប្រេង រលាយចូលក្នុងទឹក ហើយស្ថិតនៅជាយូរ។ ដូច្នេះវិធីតែមួយគត់ដើម្បីប្រាកដថាទឹកមានសុវត្ថិភាពឬអត់ គឺត្រូវធ្វើតេស្តទឹក។

## វិធីរក្សាសុវត្ថិភាពបន្ទាប់ពីកំពប់ប្រេង




- ចៀសវាងការប៉ះពាល់ប្រេង។ កុំឲ្យកុមារនិងសត្វចូលក្នុងកន្លែងកំពប់។ ប្រសិនបើអាច គួរព័ទ្ធរបងជុំវិញតំបន់នេះ រួចដាក់ស្លាកសញ្ញាព្រមាន។
- ប្រើប្រាស់ប្រភពទឹកដែលស្ថិតនៅខ្ពស់ជាងកន្លែងកំពប់។ ទោះបីអ្នកត្រូវដើរទៅឆ្ងាយក៏ដោយ វាមានប្រយោជន៍ក្នុងការបង្ការបញ្ហាសុខភាព។ នៅកន្លែងដែលមានកំពប់ប្រេង មានតែទឹកភ្លៀងទេ ដែលអាចជាទឹកសុវត្ថិភាពតែមួយគត់សម្រាប់ផឹក។
- ចៀសវាងការបរិភោគសត្វដែលរស់នៅក្នុងទឹក ដូចជាក្តាម បង្គារ ព្រមទាំងខ្យងដែលរស់នៅក្បែរកន្លែងកំពប់និងខ្សែទឹកខាងក្រោម។ ពួកវាបឺតស្រូបសារធាតុពុលដូចអេប៉ុងយ៉ាងដូច្នោះដែរ។
- ចៀសវាងងូតទឹកក្នុងទឹកដែលបានកំពប់ប្រេង។ ប្រសិនបើនរណាម្នាក់ធ្លាក់ចូលក្នុងទឹកនេះ គួរលាងសម្អាតខ្លួនភ្លាមៗ ជាមួយសាប៊ូខ្លាំងនិងទឹកស្អាត។
- រាយការណ៍ប្រាប់អ្នកជិតខាង អាជ្ញាធរ សារព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលពាក់ព័ន្ធនឹងសុខភាពនិងបរិស្ថាន។
- បង្រៀនប្រជាជននៅសាលារៀននិងទីជួបជុំក្នុងសហគមន៍ អំពីគ្រោះថ្នាក់នៃប្រេង។

# ការសម្អាតប្រេងដែលកំពប់

ការសម្អាតការកំពប់ គឺជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនប្រេង។ ក្រុមហ៊ុនទាំងឡាយតែងតែអះអាងថាគេអាចសម្អាតការកំពប់ប្រេងទាំងអស់។ ប៉ុន្តែជាក់ស្តែង សូម្បីតែមានឧបករណ៍ទំនើបបំផុតក៏ដោយ ការសម្អាតប្រេងគឺជាការងារដ៏ពិបាកនិងគ្រោះថ្នាក់។ ក្នុងករណីស្ទើរតែទាំងអស់ ប្រជាជនដែលរងការប៉ះពាល់ពីការកំពប់ប្រេង គ្មានឧបករណ៍ការពារទេ។



**នៅពេលណាមានការកំពប់ប្រេង, មិនថានៅលើទឹកឬលើដីទេ, សារធាតុគីមីនៅក្នុងប្រេង បំពុលមនុស្ស សត្វ រុក្ខជាតិ ដី និងទឹក។**

ក្រុមហ៊ុនប្រេងគួរចាប់ផ្តើមការសម្អាតភ្លាមៗនៅពេលប្រេងកំពប់។ ដោយសារសារធាតុពុលនៅក្នុងប្រេងរលាយចូលទឹកនិងជ្រាបទៅក្នុងដី ការសម្អាតតែស្រទាប់ប្រេងនៅខាងលើផ្ទៃទឹកនិងដី គឺមិនអាចសម្អាតប្រភពនៃគ្រោះថ្នាក់បានគ្រប់ពេលទេ(មើលទំព័រ514)។

## ការសម្អាតប្រេងកំពប់ ធ្វើឲ្យកម្មករឈឺ

នៅពេលកប៉ាល់ដឹកប្រេងឈ្មោះថា អិក្សសិនវ៉ាលដេស គឿងនៅត្រង់ឆ្នេរអាឡាស្កានៅឆ្នាំ១៩៨៩ វាបានកំពប់ប្រេងជាច្រើនលានលីត្រទៅក្នុងទឹក។ ប្រេងដែលកំពប់បានសម្លាប់ជីវិតសត្វនិងសត្វស្លាបច្រើនរាប់មិនអស់ និងបំផ្លាញជំនួញនេសាទក្នុងតំបន់។ រហូតមកដល់សព្វថ្ងៃ ប្រេងនៅតែបង្កការខូចខាត។

ក្រុមហ៊ុនអិក្សសិន បានជួលកម្មករចំនួន១០.០០០នាក់ឲ្យសម្អាតប្រេងកំពប់និងសង្គ្រោះជីវិតសត្វ។ ដោយប្រើប្រាស់ឧបករណ៍ល្អបំផុត ពួកគេធ្វើការពី១២ទៅ១៦ម៉ោងក្នុងមួយថ្ងៃ រយៈពេលជាច្រើនខែ ព្យាយាមសម្អាតប្រេងនិងបង្ការការសាត់អណ្តែត។ ពួកគេពាក់សម្លៀកបំពាក់ការពារដើម្បីកុំឲ្យប្រេងប៉ះនឹងស្បែក និងពាក់ម៉ាស់ដើម្បីកុំឲ្យស្រូបចំហាយពុលចូល។

នៅពេលបញ្ចប់ការងារក្នុងមួយថ្ងៃៗ កម្មករដោះអាវភ្លៀង ស្បែកជើងកវែង និងស្រោមដៃចេញ។ ពួកគេលាងសម្អាតខ្លួននិងសម្លៀកបំពាក់ការពារ ជាមួយសារធាតុគីមីរំលាយ។ នៅថ្ងៃបន្ទាប់ ពួកគេពាក់សម្លៀកបំពាក់នោះឡើងវិញ និងធ្វើការជាបន្ត។ ប៉ុន្តែទោះបីមានសម្ភារៈការពារក៏ដោយ កម្មករជាច្រើនបានត្អូញត្អែរពីការក្អក ឈឺក្បាល វិលមុខ និងហៀរសំបោរ។ កម្មករម្នាក់និយាយថា "នៅពេលយប់ ពួកយើងក្អកគ្រប់គ្នា។ វាហាក់ដូចជាស្ថិតក្នុងអាគារជំងឺរបេងអ៊ីចឹង"។ ១០ឆ្នាំក្រោយមក កម្មករជាច្រើនបានកើតមានបញ្ហាជាច្រើន ដូចជាការបាត់បង់ការចង់ចាំ ខូចសួត និងមហារីក។ ពួកគេជាច្រើនរយនាក់បានស្លាប់។

អិក្សសិនត្រូវបានប្តឹងឲ្យបង់សំណងលើការខូចខាតទាំងនេះ។ ប៉ុន្តែជាច្រើនឆ្នាំមកនេះ ពួកគេមិនទាន់បានចំណាយប្រាក់អ្វីបន្តិចសោះឡើយ។

# គួរធ្វើអ្វីខ្លះក្នុងករណីមានការកំពប់ប្រេង

នៅពេលប្រេងកំពប់ឬធ្លាយចេញពីអាងស្តុក គួរគ្រប់គ្រងនិងបឺតស្រូបប្រេងជាបន្ទាន់។ នៅពេលបឺតស្រូបវាហើយ ប្រេងនិងសម្ភារៈនានាដែលប្រើសម្រាប់បឺតស្រូប ត្រូវតែយកចេញនិងបោះចោលឲ្យមានសុវត្ថិភាព, ឧទាហរណ៍ ចោលក្នុងរណ្តៅដែលមានទ្រនាប់ស៊ីម៉ង់ត៍ ដើម្បីកុំឲ្យវាបំពុលទឹកក្រោមដី។



**សម្ភារៈមួយចំនួនដែលបឺតស្រូបប្រេងមាន ចំបើង អាចម៍រណារ ស្នូលពោត រោមសត្វ ដីឥដ្ឋ រោមចៀម និងដីខ្សាច់។**

គេអាចគ្រប់គ្រងនិងបឺតស្រូបប្រេងដែលកំពប់ក្នុងទឹក ប៉ុន្តែវាជាការងារពិបាកបើគ្មានឧបករណ៍ពិសេសទេ។ អ្នកណាដែលចូលទៅក្នុងទឹកដើម្បីសម្អាតប្រេង អាចមានជំងឺយ៉ាងធ្ងន់ធ្ងរ។ ការព្យាយាមសម្អាតប្រេងដោយដងប្រេងនឹងធុងទឹក គឺជាការងារគ្រោះថ្នាក់ និងមិនសូវមានប្រសិទ្ធភាព។ នេះគឺជាវិធីសម្អាតប្រេងដែលកំពប់ក្នុងទឹក ដោយមានឧបករណ៍ និងការបណ្តុះបណ្តាលត្រឹមត្រូវ :




ប្រេងត្រូវបានបង្ខាំងឲ្យនៅមួយកន្លែងដោយប្រើសាវ (របងអណ្តែតទឹកមួយប្រភេទដែលចងភ្ជាប់ដោយយុថ្កា) ឬដោយចងភ្ជាប់ទៅនឹងទូក ឬវត្ថុអ្វីមួយនៅលើឆ្នេរ។




សាវបង្ការប្រេងស្ទើរតែទាំងអស់ មិនឲ្យរសាត់អណ្តែតទៅឆ្ងាយ។ ម៉ាស៊ីនជួសចូកយកប្រេងចេញពីលើផ្ទៃទឹក និងបូមតាមទុយោចូលទៅក្នុងធុងស្តុកកាកសំណល់មួយ។




ប្រេងដែលនៅសល់ក្នុងទឹក ត្រូវបានបឺតស្រូបដោយប្រើសម្ភារៈដូចជាអាចម៍រណារ ស្លែពុក រោមសត្វ ឬដីឥដ្ឋ។




បន្ទាប់ពីបានជួសប្រេងនៅលើផ្ទៃទឹក បឺតស្រូប និងយកចេញរួចហើយ អ្វីដែលនៅសល់ត្រូវបានដុតចោល។ ការដុតប្រេង បង្កើតផ្សែងពុល ប៉ុន្តែអាចប្រសើរជាងការទុកឲ្យប្រេងស្ថិតនៅក្នុងទឹក។

### ប្រសិនបើអ្នកសម្អាតប្រេងកំពប់ ត្រូវការពារខ្លួន!

មិនថាអ្នកនិងសហគមន៍ត្រូវសម្អាតប្រេងកំពប់ដោយខ្លួនឯង ឬត្រូវបានជួលដោយក្រុមហ៊ុនប្រេងឲ្យសម្អាតក៏ដោយ ការសំខាន់គឺអ្នកត្រូវដឹងថា ៖

- ប្រេងតែងតែពុល។ ការប៉ះពាល់វាឬដកដង្ហើមស្រូបវាចូល អាចបណ្ដាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ(មើលទំព័រ506)។
- សារធាតុរំលាយដែលប្រើសម្រាប់សម្អាតប្រេង ក៏ពុលដែរ និងអាចបណ្ដាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរផងដែរ(មើលទំព័រ516)។
- ការបាញ់ទឹកតាមទុយោដែលមានសម្ពាធខ្ពស់ ដើម្បីជម្រះប្រេងចេញពីថ្ម ធ្វើឲ្យវា**ហួត**ជាឧស្ម័ន និងធ្វើឲ្យវាកាន់តែងាយចូលក្នុងដង្ហើមយើងទៀត។ បែបនេះបណ្ដាលឲ្យមានបញ្ហាបំពង់ក និងសួត។
- ក្រុមហ៊ុនដែលទទួលខុសត្រូវលើការកំពប់និងការសម្អាតប្រេង គួរផ្ដល់ឲ្យអ្នកនូវសម្លៀកបំពាក់ការពារ រួមមានខោនិងអាវ ស្រោមដៃ ស្បែកជើងកវែង ប្រដាប់ដកដង្ហើម វ៉ែនតាសុវត្ថិភាព និងគម្របក្បាល(មើលសេចក្ដីបន្ថែម ក)។
- ការធ្វើការងារច្រើនម៉ោងនៅក្នុងទឹកដែលប្រឡាក់ប្រេង ឬប្រឈមនឹងសារធាតុរំលាយ អាចបណ្ដាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ។ ល្អបំផុតគួរធ្វើការងារតិចម៉ោង និងសម្រាកឲ្យឆ្ងាយពីចំហាយពុលនៅចន្លោះវេនការងារនីមួយៗ។

## បង្កើតផែនការសុវត្ថិភាពសម្រាប់គ្រាអាសន្ន

ប្រសិនបើអ្នករស់នៅតំបន់ខួងប្រេងឬស្លប្រេង គួរធ្វើការជាមួយសហគមន៍អ្នកដើម្បីបង្កើតផែនការសុវត្ថិភាពមួយសម្រាប់ការពារសុខភាពមនុស្សគ្រប់គ្នាក្នុងករណីមានភាពអាសន្នណាមួយកើតឡើង ដូចជាអណ្ដាតភ្លើង ឧស្ម័ន និងការកំពប់ប្រេង។ (ដើម្បីស្វែងយល់បន្ថែមអំពីផែនការសុវត្ថិភាព សូមមើលទំព័រ545)។

### គូរផែនទីនៃសហគមន៍របស់អ្នក

ផ្នែកមួយនៃផែនការសុវត្ថិភាពគឺត្រូវដឹងថាបញ្ហាអាចកើតចេញពីត្រង់ណា និងថាតើធនធានមាននៅកន្លែងណាខ្លះ ដើម្បីបង្ការនិងស្ដារឡើងវិញពីគ្រោះអាសន្ន។ ការគូរផែនទីសហគមន៍ អាចជួយបាន។

ជាមួយអ្នកដទៃទៀតនៅក្នុងសហគមន៍ ចូរគូរផែនទីពីទីកន្លែងដែលអ្នករស់នៅ។ រួមបញ្ចូលនូវអណ្ដូងប្រេង ទីតាំងខួងប្រេង បំពង់បង្ហូរប្រេង រណ្ដៅកាកសំណល់ រោងចក្រស្លប្រេង និងប្រភពបំពុលផ្សេងទៀត។ ម្យ៉ាងទៀត រួមបញ្ចូលកន្លែងដែលអ្នកទៅយកទឹក កន្លែងដាំដំណាំ ទុកដាក់សត្វ ក៏ដូចជាធនធានទាំងឡាយក្នុងសហគមន៍។

ជជែកអំពីទីកន្លែងដែលធ្លាប់មានការកំពប់ប្រេង ឧប្បត្តិហេតុ ឬការបំពុលដោយប្រេង។ តើផលប៉ះពាល់មានអ្វីខ្លះ? គូសសម្គាល់នៅលើផែនទីត្រង់កន្លែងដែលអ្នកបានឃើញផលប៉ះពាល់នៃការកំពប់ប្រេង។ បន្ទាប់មកសរសេរបញ្ជីមួយរាយប្រភេទធនធានដែលមាននៅក្នុងសហគមន៍ ហើយបង្កើតផែនការមួយសម្រាប់ប្រើប្រាស់ធនធានទាំងនេះក្នុងករណីគ្រាអាសន្ន។



## ជួបប្រជុំគ្នា និងបង្កើតផែនការរបស់អ្នក




## របៀបចាត់ឲ្យក្រុមហ៊ុនទទួលខុសត្រូវ

ក្រុមហ៊ុនប្រេងគួររៀបចំឯកសារនៃការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន(EIA) មុននឹងការខួងប្រេងចាប់ផ្តើម។ ឯកសារEIA បញ្ជាក់ប្រាប់ថាតើក្រុមហ៊ុនត្រូវទទួលខុសត្រូវលើអ្វីខ្លះក្នុងករណីមានការកំពប់ប្រេង។ ពិភាក្សាថាតើសហគមន៍របស់អ្នកអាចប្រើប្រាស់ឯកសារEIA ដើម្បីចាត់ក្រុមហ៊ុនឲ្យទទួលខុសត្រូវចំពោះគ្រោះអាសន្នយ៉ាងដូចម្តេច។ ឧទាហរណ៍ តើអ្នកអាចទាមទារឲ្យពួកគេបិទបំពង់បង្ហូរប្រេងរហូតសម្អាតប្រេងកំពប់រួច បានឬទេ? តើក្រុមហ៊ុនអាចផ្គត់ផ្គង់សហគមន៍នូវទឹកផឹក ឬបង់ថ្លៃសេវាសុខភាពនិងការខូចខាតទ្រព្យសម្បត្តិឬទេ? (ដើម្បីស្វែងយល់បន្ថែមអំពីឯកសារEIA សូមមើលសេចក្តីបន្ថែម ខ)។

# ការស្តារដីដែលបានបំផ្លាញដោយប្រេងឡើងវិញ

ប្រេងកំពប់បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរយូរអង្វែងមកលើដី។ ប្រសិនបើបានសម្អាតប្រេង រួចទុកដីចោលឲ្យវាបានប្រសើរឡើងវិញជាច្រើនឆ្នាំ នោះវាអាចមានជីជាតិឡើងវិញបាន។ ប៉ុន្តែវានឹងត្រូវការពេលយូរយារណាស់។ (សម្រាប់ព័ត៌មានបន្ថែមអំពីការកែប្រែដីឡើងវិញ សូមមើលជំពូក11 និងទំព័រ496)។



## វិធីសាស្ត្រថ្មីក្នុងការសម្អាតប្រេងកំពប់?

បន្ទាប់ពីប្រេងម៉ាស៊ូតកំពប់នៅក្នុងសហរដ្ឋអាមេរិក ក្រុមហ៊ុនជាច្រើនត្រូវបានស្នើឲ្យទៅពិនិត្យមើលថាតើគេអាចធ្វើអ្វីខ្លះដើម្បីសម្អាតវា។ ប្រេងកំពប់ត្រូវបានគៀរជាគំនរៗ ហើយក្រុមហ៊ុននីមួយៗបានធ្វើការនៅលើគំនរមួយ។

ក្នុងនោះមានក្រុមហ៊ុនតូចមួយដែលជាអ្នកដាំនិងលក់ផ្សិតហូបបាន។ បុរសម្ចាស់ជំនួញនេះ បានសង្កេតឃើញថាផ្សិតលូតលាស់បន្ទាប់ពីភ្លើងឆេះព្រៃ និងមហន្តរាយធម្មជាតិដទៃទៀត។ គាត់ជឿជាក់ថាផ្សិតមានអំណាចក្នុងការកែប្រែដីដែលខូច។ ក្រុមហ៊ុនរបស់គាត់បានដាំផ្សិតនៅលើគំនរដីដែលជោគជាំដោយប្រេង។ បន្ទាប់មកពួកគេគ្របគំនរនេះ ហើយរង់ចាំមួយរយៈ។

៦សប្តាហ៍ក្រោយមក ពួកគេបើកគម្រប ហើយឃើញរឿងអស្ចារ្យមួយ។ ដីនេះត្រូវបានគ្របដណ្តប់ដោយផ្សិតធំៗ ខ្លះមានទំហំ៣០ស.មឯណោះ។ ពួកគេយកផ្សិតនិងដីទៅធ្វើតេស្តនៅមន្ទីរពិសោធន៍។ ផ្សិតគ្មានជាតិប្រេងឬសារធាតុគីមីពុលដែលមាននៅក្នុងប្រេងឡើយ។ ផ្សិតបានសម្អាតប្រេងទាំងស្រុងយ៉ាងពិតប្រាកដ!

ផ្នែកដ៏អស្ចារ្យនៃសាច់រឿងនេះ គឺអ្វីដែលកើតឡើងបន្ទាប់។ បន្ទាប់ពីផ្សិតទំ រុយបានហើរមកពងលើវា។ បន្ទាប់មកក៏ចេញដង្កូវ, សត្វស្លាបក៏ហើរចុះមក, ហើយសត្វតូចៗដទៃទៀតក៏ចាប់ផ្តើមចូលមកស៊ីផ្សិតនិងដង្កូវ។ សត្វស្លាបនិងសត្វផ្សេងៗបាននាំគ្រាប់ពូជមកទីនេះ ហើយរុក្ខជាតិក៏ចាប់ផ្តើមដុះឡើង។ គំនរដីដ៏កខ្វក់បានប្រែក្លាយទៅសួនដំណាំយ៉ាងរស់រវើក។

វិធីសាស្ត្រនេះមានប្រសិទ្ធភាពនៅក្នុងការពិសោធន៍ ប៉ុន្តែមិនទាន់មាននរណាដឹងថាវានឹងមានប្រសិទ្ធភាពនៅគ្រប់ស្ថានភាពនិងទីកន្លែងទាំងអស់នោះទេ។ ត្រូវធ្វើពិសោធន៍ថែមទៀត ដើម្បីបញ្ជាក់ថាផ្សិត ឬ "ឱសថធម្មជាតិ"ដទៃទៀត អាចសម្អាតប្រេងកំពប់បាន។

# យុត្តិធម៌ផ្នែកបរិស្ថាន

វិធីសំខាន់មួយដែលប្រជាជនរស់នៅក្នុងតំបន់សម្បូរប្រេង អាចការពារសុខភាពរបស់ខ្លួន គឺត្រូវធ្វើឲ្យប្រាកដថា នរណាក៏ដោយដែលគ្រប់គ្រងធនធានប្រេង ត្រូវធ្វើការងារក្នុងរបៀបមួយដែលការពារប្រជាជនពីការប្រឈមគ្រោះថ្នាក់លើសុខភាព និងផ្តល់ផលប្រយោជន៍ដល់ប្រជាជន។ ដោយសារប្រេងមានតម្លៃខ្លាំងណាស់ ដូច្នេះពួកគេមានទ្រព្យសម្បត្តិច្រើនដើម្បីការពារប្រជាជនបាន។




## ស្ត្រីតវ៉ាប្រឆាំងនឹងការរុករកប្រេង

តំបន់ដីសណ្តទន្លេនីហ្សេក្នុងប្រទេសនីហ្សេរីយ៉ា ធ្លាប់ជាដីដែលសម្បូរជីជាតិ ជាមួយនឹងត្រី សត្វព្រៃ និងកសិដ្ឋានជាច្រើន។ នៅពេលក្រុមហ៊ុនប្រេងទាំងឡាយមកដល់ភូមិភាគនេះដំបូង ពួកគេបានសន្យាថានឹងផ្តល់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចរបស់ប្រជាជនគ្រប់គ្នា។ ប៉ុន្តែបន្ទាប់ពីការអភិវឌ្ឍន៍ប្រេងជាង ៣០ឆ្នាំមកហើយ ពួកគេមិនបានធ្វើតាមសម្តីរបស់ខ្លួនឡើយ។ ស្ត្រីនីហ្សេរីយ៉ាម្នាក់ពន្យល់ថា "ពួកយើងខឹងសម្បារខ្លាំងណាស់។ ចាប់ពីឆ្នាំ១៩៧០មក នៅពេលក្រុមហ៊ុនមកដល់ទីនេះ ពួកគេបានកាត់ផ្តាច់អ្វីគ្រប់យ៉ាងពីពួកយើង។ យើងគ្មានអ្វីបង្ហាញទេ គឺមានតែការបំពុលនៅក្នុងទន្លេនិងព្រៃករបស់យើង, និងសំឡេងលាន់ខ្លាំងៗនៃអណ្តាតភ្លើងឧស្ម័ន។ ពួកយើងគ្មានសង្ឃឹមអ្វីឡើយ ខណៈដែលពួកគេប្រើប្រាស់អំណោយរបស់យើងដែលបានមកពីព្រះដើម្បីរកប្រាក់ជាច្រើនលាន។ ពួកគេមិនខ្វល់ពីយើង ឬស្តាប់ពាក្យការយំស្រែករបស់យើងឡើយ"។

(សាច់រឿងបន្តទៅទំព័របន្ទាប់)

ស្ត្រីនីហ្សេរីយ៉ាបានចាប់ផ្ដើមយុទ្ធនាការតវ៉ាដោយសន្តិភាពមួយដែលមានការចូលរួមពីកុលសម្ព័ន្ធទាំងអស់នៅក្នុងភូមិភាគនេះ។ ស្ត្រីទាំងនេះទាមទារក្រុមហ៊ុនឆេវរ៉ុនតិចសាកូ ដែលជាក្រុមហ៊ុនដ៏ចម្បងមួយធ្វើការនៅក្នុងភូមិភាគនេះ ឲ្យផ្ដល់ការងារ, ធនធានសម្រាប់ការអប់រំ, ទឹក, អគ្គិសនី, និងការអភិវឌ្ឍន៍សហគមន៍។ ហើយពួកគេបានទាមទារប្រាក់សំណងនូវរាល់ការខូចខាតទាំងឡាយដែលក្រុមហ៊ុនបានធ្វើកន្លងមក។

ក្រុមហ៊ុនឆេវរ៉ុនតិចសាកូ បានសុំឲ្យរដ្ឋាភិបាលឆ្លើយតបដោយកណ្ដាប់ដៃដែក។ ប៉ូលីសនិងទាហានបានបាញ់ឧស្ម័នបង្ហូរទឹកភ្នែក និងវាយដំច្រំធាក់លើស្ត្រីទាំងអស់។ ស្ត្រីជាច្រើនបានរងរបួស ហើយខ្លះទៀតបានបាត់បង់ជីវិត។ ប៉ុន្តែស្ត្រីបានឆ្លើយតបដោយភាពមោះមុត និងភាពបត់បែន។ ស្ត្រីមួយចំនួនបានទៅរារាំងមិនឲ្យបុគ្គលិកធ្វើការនៅការិយាល័យកណ្ដាល, ខ្លះទៀតទៅកាន់កាប់នៅចំណតនាំចេញ, និងជាច្រើនរយនាក់ទៀតទៅកាន់កាប់ស្ថានីយបង្ហូរចំនួន៤នៅក្នុងទន្លេនីហ្សេ ដើម្បីបញ្ឈប់ក្រុមហ៊ុនមិនឲ្យដឹកប្រេងចេញតាមកប៉ាល់។ ក្រុមហ៊ុនឆេវរ៉ុនតិចសាកូបានខាតបង់ជាង១០០.០០០ដុល្លាក្នុង១ថ្ងៃ ពេលដែលស្ត្រីចូលកាន់កាប់ចំណតនិងស្ថានីយបង្ហូរប្រេង!

ចុងក្រោយ ក្រុមហ៊ុនប្រេងបានសុខចិត្តចុះចាញ់។ ពួកគេបានយល់ព្រមបង្កើតការងារ និងបង្កើតកម្មវិធីឥណទានខ្នាតតូចដើម្បីជួយស្ត្រីឲ្យចាប់ផ្ដើមជំនួញរបស់ខ្លួន។ ពួកគេក៏បានសន្យាថានឹងផ្ដល់សាលារៀន មន្ទីរពេទ្យ ទឹកនិងអគ្គិសនីសម្រាប់ភូមិទាំងឡាយផងដែរ។

សកម្មភាពព្រៃផ្សៃរបស់ក្រុមហ៊ុនប្រេងនិងដៃគូរដ្ឋាភិបាលរបស់ពួកគេនៅក្នុងប្រទេសនីហ្សេរីយ៉ា បង្ហាញថាពួកគេនឹងមិនបញ្ឈប់ការបង្កើនប្រាក់ចំណូលរបស់ខ្លួនឡើយ ទោះជាមានរឿងអ្វីកើតឡើងក៏ដោយ។ ស្ត្រីក្នុងប្រទេសនីហ្សេរីយ៉ាបានផ្ដល់កម្លាំងចិត្តដល់ប្រជាជននៅទូទាំងពិភពលោក ឲ្យទាមទារផលប្រយោជន៍មួយចំណែកពីការអភិវឌ្ឍន៍ គឺមិនមែនទទួលតែភាពវេទនាទេ។ បើមិនដូច្នេះទេ ពួកគេនឹងបញ្ឈប់ការអភិវឌ្ឍន៍ប្រេងទាំងអស់គ្នា។

# ប្រេង និងច្បាប់

ប្រទេសជាច្រើនបង្កើតច្បាប់ដើម្បីការពារប្រជាជន ទឹក និងសត្វព្រៃ ពីការបំពុល, និងដើម្បីទទួលបានលក្ខខណ្ឌការងារសុវត្ថិភាព។ ច្បាប់និងកិច្ចព្រមព្រៀងក្នុងភូមិភាគនិងអន្តរជាតិ ក៏ត្រូវបានបង្កើតឡើងដើម្បីចាត់ឲ្យក្រុមហ៊ុនប្រេងទទួលខុសត្រូវលើការកំពប់នានា។ ប៉ុន្តែច្បាប់ទាំងនេះមានប្រសិទ្ធភាព លុះត្រាតែប្រជាជនធ្វើការរួមគ្នាដើម្បីប្រាកដថាច្បាប់ត្រូវបានអនុវត្តប៉ុណ្ណោះ។ (សម្រាប់ព័ត៌មានបន្ថែមអំពីច្បាប់អន្តរជាតិ សូមមើលសេចក្ដីបន្ថែម ខ)។

## បណ្ដឹងប្រឆាំងនឹងក្រុមហ៊ុនតិចសាកូ

នៅពេលក្រុមហ៊ុនតិចសាកូបានមកខួងប្រេងនៅប្រទេសអេក្វាឌ័រ ជនជាតិដើមខូហ្វាន នៅទីនោះ មិនដឹងថាក្រុមហ៊ុនប្រេងអាមេរិកនឹងបំផ្លាញជីវិតរបស់ពួកគេទេ។ រយៈពេលជាង២០ឆ្នាំ ក្រុមហ៊ុនបានចាក់ប្រេងនិងទឹកសំណល់ពុលជាច្រើនលានលីត្រទៅក្នុងបរិស្ថាន។

ទន្លេដែលធ្លាប់តែទ្រទ្រង់ជនជាតិខូហ្វានជាច្រើនជំនាន់មកហើយ បានក្លាយជាប្រភពអាហារដែលគ្មានប្រយោជន៍។ រៀងរាល់ថ្ងៃប្រជាជនចំណាយពេលជាច្រើនម៉ោងដើម្បីស្វែងយកទឹកដែលអាចផឹកបាន និងបរបាញ់សត្វ។ ប្រជាជនជាច្រើនបានរត់ចេញពីតំបន់នេះ ដោយសារការបំផ្លាញបរិស្ថាន។ អ្នកដឹកនាំរបស់ជនជាតិខូហ្វាន និយាយថាក្រុមហ៊ុនតិចសាកូបានបំផ្លាញរបៀបរស់នៅបែបបុរាណរបស់ពួកគេ និងបង្កឲ្យមានជំងឺដល់ប្រជាជនរាប់ពាន់នាក់។ អាត្រាជនជាតិខូហ្វានបានធ្លាក់ពី១៥.០០០នាក់ មកត្រឹមប្រហែល៥០០នាក់ប៉ុណ្ណោះ។




ជនរងគ្រោះពីការបំពុលរបស់ក្រុមហ៊ុនតិចសាកូ បានបង្កើតជារណសិរ្សការពារព្រៃអាម៉ាហ្សូន។ ពួកគេ រៀបចំការថែទាំសុខភាពសម្រាប់ប្រជាជនដែលមានជំងឺធ្ងន់ធ្ងរ។ ពួកគេបានជួយរៀបចំការសិក្សាអំពីផលប៉ះពាល់លើសុខភាពពីប្រតិបត្តិការប្រេងរបស់ក្រុមហ៊ុនតិចសាកូ។ ពួកគេបានជជែកជាមួយសកម្មជនផ្នែកបរិស្ថានពីរដ្ឋធានីគីតូ រហូតដល់មេធាវីក្នុងសហរដ្ឋអាមេរិក។ ពួកគេបានបង្កើតផែនការមួយ។ អ្នកដឹកនាំនិងសកម្មជនបានធ្វើដំណើរថ្មើជើង តាមទូក និងយន្តហោះ ទៅក្រុងញូយ៉កដើម្បីដាក់ពាក្យប្តឹងក្រុមហ៊ុនតិចសាកូ នូវទឹកប្រាក់មួយកោដិដុល្លា។

ក្រុមហ៊ុនតិចសាកូបានព្យាយាមធ្វើយ៉ាងណាដើម្បីឲ្យមានការលើកបណ្តឹងចោល។ ក្រុមហ៊ុននេះបានអះអាងថាបណ្តឹងនេះគួរធ្វើឡើងនៅតុលាការអេក្វាឌ័រ ព្រោះការបំពុលបានកើតឡើងនៅទីនោះ។ សកម្មជនទាំងឡាយបារម្ភថាពួកគេពិបាកនឹងទទួលបានយុត្តិធម៌នៅក្នុងប្រទេសអេក្វាឌ័រ។ ពួកគេពន្យល់ចៅក្រមថា ការសម្រេចចិត្តឲ្យបំពុលព្រៃអាម៉ាហ្សូន គឺត្រូវបានធ្វើឡើងនៅក្នុងសហរដ្ឋអាមេរិក។ ចៅក្រមក៏យល់ព្រមស្តាប់ពួកគេ។ នេះគឺជាលើកទីមួយដែលបណ្តឹងអន្តរជាតិត្រូវបានទទួលនៅក្នុងតុលាការអាមេរិក! អ្នកដឹកនាំជនជាតិខូហ្វាន សប្បាយរីករាយជាខ្លាំង។

រយៈពេល១០ឆ្នាំ ក្រុមហ៊ុនតិចសាកូបានតស៊ូដើម្បីលើកបណ្តឹងចោល។ ចៅក្រមថ្មីម្នាក់បានសម្រេចថា បណ្តឹងនេះគួរជំនុំជំរះនៅក្នុងប្រទេសអេក្វាឌ័រ ប៉ុន្តែប្រសិនបើគ្មានលទ្ធផលយុត្តិធម៌ទេ បណ្តឹងនេះអាចជំនុំជំរះឡើងវិញនៅក្រុងញូយ៉ក។ រឿងក្តីនេះមិនទាន់ចប់នៅឡើយទេ។ ប្រជាជននៅតែបន្តរងគ្រោះដោយសារការចាក់ប្រេងនៅខាងក្រៅព្រៃទឹកភ្លៀង។ ការតស៊ូទាមទារយុត្តិធម៌យ៉ាងស្វិតស្វាញរបស់ពួកគេ បានបង្រៀនប្រជាជនជាច្រើនអំពីការបំផ្លាញដោយសារប្រេង និងបានបង្ខំឲ្យក្រុមហ៊ុនតិចសាកូនិងក្រុមហ៊ុនប្រេងដទៃទៀត ប្រើប្រាស់មធ្យោបាយខួងប្រេងដែលមានសុវត្ថិភាពជាងមុន។